**គោលនយោបាយសង្ខេប**

ស្តីពី

# "កត្តាដែលជះឥទ្ធិពលដល់ភាពជោគជ័យនៃវិមជ្ឈការសារពើពន្ធនៅកម្ពុជា"

ខែវិច្ឆិកា ឆ្នាំ២០១២

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា


សេចក្តីសង្ខេប ................................................................................................ 3

I: សេចក្តីផ្តើម ...................................................................................................9

II: ការចាត់ចែងមូលនិធិបច្ចុប្បន្នដើម្បីបំពេញអាណត្តិរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ ......................14

III: ការសម្របសម្រួល និងការចាត់ចែងមុខងាររវាងថ្នាក់ក្រោមជាតិ និងក្រសួង ថ្នាក់ជាតិ .............16

IV: មូលនិធិឃុំ/សង្កាត់ (CSF) ........................................................................... 20

V: មូលនិធិសម្រាប់ការផ្តល់សេវាតាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក .......................21

VI: សមត្ថភាព ........................................................................................... 23

VII: ប្រភពចំណូលផ្ទាល់ខ្លួន

VIII: កត្តាផ្សេងៗទៀតដែលជះឥទ្ធិពលដល់ភាពជោគជ័យនៃវិមជ្ឈការសារពើពន្ធ .......................26

IX: សន្និដ្ឋាន ...................................................................................................28

X: អនុសាសន៍ ...................................................................................................29

គន្ថនិទ្ទេស ................................................................................................ 33

**វិទ្យាស្ថានសភាកម្ពុជា**

**ការវិភាគគោលនយោបាយ**

**កត្តាដែលជះឥទ្ធិពលដល់ភាពជោគជ័យនៃវិមជ្ឈការសារពើពន្ធនៅកម្ពុជា**


## សេចក្តីសង្ខេប

ទម្រង់វិមជ្ឈការរួមមាន៖ "វិមជ្ឈការនយោបាយ" ផ្តល់ដល់ប្រជាពលរដ្ឋ និងតំណាងជាប់ឆ្នោតរបស់ពួកគាត់នូវអំណាចច្រើនជាងមុនក្នុងការធ្វើសេចក្តីសម្រេចជា សាធារណៈ"វិមជ្ឈការតាមបែបប្រជាធិបតេយ្យ" ការបោះឆ្នោតមូលដ្ឋានរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ (SNAs) "វិមជ្ឈការរដ្ឋបាល" ដែលការទទួលខុសត្រូវ និងធនធានត្រូវអនុវត្តត្រូវផ្ទេរពីក្រសួងថ្នាក់កណ្តាលទៅឱ្យមន្ទីរខ្សែបណ្តោយ នៅថ្នាក់ក្រោមជាតិ ("វិសហមជ្ឈការ") ឬទៅឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិដើម្បីអនុវត្តដោយឯករាជ្យ "ប្រតិភូកម្ម" "វិមជ្ឈការសារពើពន្ធ "ជាការផ្ទេរការទទួល ខុសត្រូវផ្នែកហិរញ្ញវត្ថុទៅឱ្យអាជ្ញាធរមូលដ្ឋានដើម្បីបំពេញមុខងារតាមអាណត្តិ។

គោលដៅសំខាន់របស់រាជរដ្ឋាភិបាលនៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (SNDD) គឺលើកកម្ពស់ការបំរើសេវាកម្មមូលដ្ឋានឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គល និងក្រុមគ្រួសារ ។ វិមជ្ឈការ សារពើពន្ធមានសារៈសំខាន់ចំពោះការអនុវត្តដំណើរការនេះ។ ថ្នាក់ទាបបំផុតនៃអាជ្ញាធរថ្នាក់ក្រោមជាតិនៅកម្ពុជាគឺ ឃុំ/សង្កាត់ដែលមានអាណត្តិបង្កើតថវិកាផ្ទាល់ខ្លួនដើម្បីបំរើសេវាកម្មដែលលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងតម្លើងស្តង់ដារជីវភាពរបស់ប្រជាជន ហើយទាំងនេះតម្រូវឱ្យមានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីសម្រេចតាមគោលដៅទាំងនេះ។ ដំណាក់កាលបន្ទាប់នៃវិមជ្ឈការហិរញ្ញវត្ថុ គឺពាក់ព័ន្ធនឹងការផ្តល់មូលនិធិទៅឱ្យថ្នាក់ស្រុក/ក្រុង ហើយការប្រគល់ប្រាក់លើកដំបូងក្រោមមូលនិធិនេះនឹងប្រព្រឹត្តទៅនៅឆ្នាំ ២០១៣។

កំណែទម្រង់នេះស្ថិតនៅដំណាក់កាលដំបូងនៅឡើយ ហើយដើម្បីទទួលបានវិមជ្ឈការសារពើពន្ធទូលំទូលាយនិងមានប្រសិទ្ធភាពជាងនេះ ដែលអាចសម្រេចបានតាមគោលដៅរបស់រាជរដ្ឋាភិបាលចំពោះ SNDD មានលក្ខខណ្ឌគន្លឹះមួយចំនួនបានមកពីការអនុវត្តល្អបំផុតជាអន្តរជាតិដែលចាំបាច់ ត្រូវដោះស្រាយ នៅដំណាក់កាលបន្ទាប់នៃកំណែទម្រង់ ដូចដែលគោលដៅ SNDD បានផ្លាស់ប្តូរនៅថ្នាក់ស្រុក។ ប្រព័ន្ធអន្តររដ្ឋាភិបាលចំពោះកំណែទម្រង់នេះត្រូវតែមានការសម្របសម្រួលឱ្យបានល្អនៅតាមក្រសួងផ្សេងៗជាមួយនឹងការគាំទ្រច្បាស់លាស់ចំពោះកំណែទម្រង់នេះ។ ខណៈដែលក្រសួងនានាធ្វើការដើម្បីសម្រេចឱ្យបានតាមគោលដៅវិមជ្ឈការដោយកំណត់ពីមុខងារ និងធនធានចាំបាច់សម្រាប់អាជ្ញាធរមូលដ្ឋានទាំងនេះផ្តល់ដល់អាជ្ញាធរថ្នាក់ក្រោមជាតិនូវលទ្ធភាព ជំនឿចិត្ត និងអាណត្តិច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពដោយឯករាជ្យ ដោយមិនមានការអន្តរាគមន៍ និងការត្រួតពិនិត្យច្រើនពេកពីថ្នាក់ខ្ពស់ជាង។

ដំណើរការនៃការប្រគល់ "មុខងារ" ពីក្រសួងនានានេះ ត្រូវកើតឡើងមុនពេលការប្រគល់ហិរញ្ញវត្ថុទៅថ្នាក់ក្រោម ដើម្បីអនុញ្ញាតឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិដឹងថាការប្រើប្រាស់មូលនិធិទៅលើអ្វីខ្លះ ហើយប្រជាពលរដ្ឋអាចតាមដានអាជ្ញាធរថ្នាក់ក្រោមជាតិបាន ។ ការផ្តល់មូលនិធិត្រូវតែ គ្រប់គ្រាន់ដើម្បីសម្រេចបានអាណត្តិរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ និងត្រូវផ្តល់ទៅឱ្យតាមរយៈការរួមបញ្ចូលរវាងការផ្ទេរពីថ្នាក់កណ្តាល និងចំណូលនៅតាមមូលដ្ឋាន ដូចជាពន្ធខ្នាតតូច ឬថ្លៃសេវា របស់អ្នកប្រើប្រាស់បានពីសេវាកម្ម ។ អាជ្ញាធរថ្នាក់ក្រោមជាតិក៏ចាំបាច់ ត្រូវមានសមត្ថភាព គ្រប់គ្រាន់ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុ និងបំពេញភារកិច្ច ដូចជាគណនេយ្យ និងថវិកា។ វិធានវិមជ្ឈការ ត្រូវតែច្បាស់សាមញ្ញ និងផ្សព្វផ្សាយជាសាធារណៈឱ្យបានត្រឹមត្រូវ ប៉ុន្តែសមត្ថភាពនេះនៅខ្វះខាតនៅឡើយ ហើយដើម្បីដោះស្រាយភាពខុសប្លែកគ្នារវាងតំបន់នៅក្នុងប្រទេស បញ្ញត្តិស្តីពីវិមជ្ឈការត្រូវតែមានភាពបត់បែន

និងតាមលំដាប់ ដើម្បីអនុញ្ញាតឱ្យតំបន់ខ្លះធ្វើអន្តរកម្មចំពោះការទទួលខុសត្រូវថ្មី នៅពេលដែលពួកគាត់ត្រៀមខ្លួនរួច។

ការត្រួតពិនិត្យលើមុខងារពាក់ព័ន្ធនឹងការវិភាគលើវិស័យមួយ និងការសម្រេចថាមុខងារ និងធនធានមួយណា ភ្ជាប់ជាមួយត្រូវបានផ្ទេរទៅថ្នាក់ផ្សេងនៃអាជ្ញាធរថ្នាក់ក្រោមជាតិ។ នេះជានីតិ វិធីវែង និងស្មុគស្មាញ ដែលត្រូវការការគាំទ្រខ្លាំងក្លាពីក្រសួង និងយន្តការសម្របសម្រួលដែលមានប្រសិទ្ធភាពទាំងអស់។ នាពេលបច្ចុប្បន្ន ទោះបីជាមាន អាណត្តិដ៏ធំសម្រាប់ការអភិវឌ្ឍមូលដ្ឋានក៏ដោយ ក៏បញ្ហាដូចជាការផ្តល់មូលនិធិ សមត្ថភាព និងភាពទប់ទល់ពីថ្នាក់ក្រសួងអាចមានន័យថា អាជ្ញាធរថ្នាក់ ក្រោមជាតិ ត្រូវជ្រើសឡើង និងមានទំនួលខុសត្រូវរៀងៗខ្លួននៅក្នុងវិស័យសំខាន់ៗតែប៉ុណ្ណោះ។ SNDD គឺជាកំណែទម្រង់ រដ្ឋាភិបាលទាំងមូល ហើយគឺជាតម្រូវការសម្រាប់ចក្ខុវិស័យរយៈពេលវែងដែលរួមបញ្ចូលការងាររបស់ ក្រសួងជាមួយនឹងគោលដៅរបស់ SNDD។ ច្បាប់អង្គការឆ្នាំ ២០០៨ បានកំណត់មុខងារថ្មី និង ធនធានសារពើពន្ធទៅឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិ ប៉ុន្តែក្នុងលក្ខខណ្ឌទូទៅប៉ុណ្ណោះ ហើយនេះអាចមាន ន័យថាក្រសួងនានានៅតែបន្តផ្តោតទៅលើគោលដៅ និងគោលនយោបាយរៀងៗខ្លួន ដោយមិនចាំ បាច់សម្របសម្រួលជាមួយកំណែទម្រង់ SNDD នោះទេ។ លើសពីនេះ នៅក្នុងវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍថ្នាក់មូលដ្ឋាន ដូចជាវិស័យសុខាភិបាល ការអប់រំ និងធនធានធម្មជាតិ សេចក្តីសម្រេចភាគច្រើននៅតែធ្វើឡើងនៅថ្នាក់កណ្តាល ទោះបីជាក្រៅពីថ្នាក់ក្រសួងដែលមានការិយាល័យ និង បុគ្គលិកនៅតាមថ្នាក់ខេត្ត និងស្រុកក៏ដោយ ហើយជារឿយៗមានកង្វះខាតនៃការបញ្ចេញឱ្យដឹងពីព័ត៌មាន លម្អិតនៃតម្លៃក្នុងការអនុវត្តមុខងារខុសៗគ្នា។

ការផ្តល់មូលនិធិដល់ការបំរើសេវាកម្មមូលដ្ឋានជាចំបងបានមកពីបានមកតាមរយៈមូលនិធិឃុំ/សង្កាត់ (CSF) ។ នេះជាកត្តាសំខាន់ក្នុងការកសាងទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ/សង្កាត់ និង ប្រជាពលរដ្ឋ និងបាន ជួយដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស ដែលផ្តល់ ផលចំណេញរាប់លាន និង

បានលើកកម្ពស់សមត្ថភាពក្រុមប្រឹក្សាឃុំ/សង្កាត់តាមរយៈ "រៀនពីការអនុវត្ត"។ ក៏ប៉ុន្តែ CSF នៅតែតំណាងឱ្យតែការចំណាយលើវិស័យសាធារណៈមួយផ្នែកតូចប៉ុណ្ណោះ (2.8% នៃចំណាយផ្សេងៗក្នុងឆ្នាំ ២០១១) ហើយនេះនៅតែមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបឱ្យបានពេញលេញទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងអាណត្តិរបស់ឃុំ/សង្កាត់។ មូលនិធិនេះត្រូវបានប្រើប្រាស់សម្រាប់ហេដ្ឋា រចនាសម្ព័ន្ធខ្នាត តូចជាជាងប្រើសម្រាប់ ការបំរើសេវាកម្មជាច្រើនដែលអាចបំពេញតាមតម្រូវការជាច្រើនរបស់ប្រជា ពលរដ្ឋ។ ទោះបីជា តម្រូវការខាង សេវាកម្មអាចត្រូវបានបំពេញដោយអ្នកផ្តល់ឱ្យតាមរយៈការងារ សមាហរណ កម្មស្រុកក៏ដោយ (DIW) ក៏យន្តការមួយដែលមានប្រសិទ្ធភាពក្នុងការបំរើសេវាកម្មផ្សេងៗ ត្រូវបាន ទិន្នន័យបានបង្ហាញឱ្យឃើញថាតួអង្គដូចជាក្រសួងខ្សែបណ្តោយ និងអង្គការក្រៅ រដ្ឋាភិបាល ទំនងជាផ្តល់មូលនិធិតាមគម្រោងរៀងខ្លួន ឬបានបង្កើតរួចជាស្រេចនូវផែនការមុនពេល ដែលពួកគាត់ចូលរួម ក្នុង DIW ហើយទាំងនេះតែងតែឆ្លុះបញ្ចាំងពីការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ។

សមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅគ្រប់កម្រិតអាជ្ញាធរថ្នាក់ក្រោមជាតិ ស្ថិតក្នុងការអភិវឌ្ឍនៅឡើយ។ ការបំពេញភារកិច្ច ដូចជាការបង្កើតថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវរារាំងដោយបញ្ហាការអប់រំ និង ជំនាញនៅមានកម្រិតទាបនៅឡើយនៅថ្នាក់មូលដ្ឋាន។ ជាឧទាហរណ៍ តាមការសិក្សារបស់សម្ព័ន្ធភាព ជាតិឃុំ/សង្កាត់ (NLC/S) មានតែក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន 18% នៅឆ្នាំ ២០១១ ប៉ុណ្ណោះដែល មានអារម្មណ៍ថាពួកគាត់បានរៀបចំថវិកាដោយខ្លួនផ្ទាល់។ លើសពីនេះ ក្រុមប្រឹក្សាឃុំ/សង្កាត់ជាច្រើនមាន ការទទួលខុសត្រូវខុសៗគ្នា ហើយពួកគាត់តែងតែចំណាយពេលច្រើនរកស៊ីចិញ្ចឹមជីវិត ដោយសារតែ ប្រាក់ខែទាប។ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំសង្កាត់មួយចំនួននៅមានកម្រិតក្នុងការដាក់សំណើសុំមូលនិធិ និងរៀបចំគម្រោងអភិវឌ្ឍន៍ ហើយលិខិតបទដ្ឋានអាចនៅតែមានភាពស្មុគស្មាញច្រើនចំពោះ ក្រុមប្រឹក្សាឃុំ/សង្កាត់ជាច្រើនក្នុងការអនុវត្ត។ ការបណ្តុះបណ្តាលជាតរឿងសំខាន់ ប៉ុន្តែក្រុមប្រឹក្សា ឃុំ/សង្កាត់ត្អូញ

ផ្សេរពេលខ្លះថាពេលវេលាមិនគ្រប់គ្រាន់ ការបណ្តុះបណ្តាលធ្វើញឹកញាប់ពេក និងវិធីសាស្ត្រមិនគ្រប់គ្រាន់។

នាពេលបច្ចុប្បន្ន ទោះជាមាន ការផ្តល់អំណាចឱ្យថ្នាក់មូលដ្ឋានប្រមូលពន្ធក៏ដោយ ក៏ក្នុងការអនុវត្តឃុំ/សង្កាត់ ប្រមូលតែថ្លៃ សេវារដ្ឋបាលមួយចំនួនដូចជាសម្រាប់សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រ មរណភាពប៉ុណ្ណោះ។ កង្វះការព្រមព្រៀងលើការចាត់ចែងការទទួលខុសត្រូវខាងការយកពន្ធ និងមូល ដ្ឋានពន្ធទាបរារាំងឃុំ/សង្កាត់លើការប្រមូលចំណូលផ្ទាល់ខ្លួន។ ក៏ប៉ុន្តែ ការប្រមូលពន្ធមូលដ្ឋានមិនផ្លូវការកើតមានតាមរយៈពន្ធ និងថ្លៃសេវាលើការជួញដូរផលិតផល ដូចជាជ័រទឹក និងត្រី ហើយទាំងនេះអាចក្លាយជាពន្ធផ្លូវការ ឬឃុំ/សង្កាត់អាចទទួលយកការប្រមូលថ្លៃសេវាប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំតិចតួចពីអ្នកជួញដូរតាមផ្សារ ដែលបច្ចុប្បន្នកំពុងតែអនុវត្តនៅតាមថ្នាក់ស្រុក និងខេត្ត និងបណ្តាធុរកិច្ចមូលដ្ឋានសាមញ្ញផ្សេងទៀត។ ការយកថ្លៃសេវាតិចតួចពីអ្នកប្រើប្រាស់លើសេវាកម្ម អនុញ្ញាតឱ្យឃុំ/សង្កាត់មានហិរញ្ញវត្ថុច្រើនជាងមុន និងផ្តល់នូវការលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យថាតើការចំណាយប្រាក់កាសប្រព្រឹត្តទៅយ៉ាងដូចម្តេច ដែលអាចឱ្យអ្នកក្រីក្រ បំផុតមិនទទួលរងការលំបាក ហើយការប្រមូលមានតម្លាភាព។

ក្រៅពីជោគជ័យនៃកំណែទម្រង់ SNDD ការសម្របសម្រួលខ្លាំងជាងនៃប្រព័ន្ធរដ្ឋាភិបាលសម្រាប់ SNDD គឺប្រហែលជាតម្រូវការចំបងបំផុតសម្រាប់កំណែទម្រង់នាពេលអនាគត។ អាណត្តិមិនច្បាស់លាស់ ថវិកាមិនគ្រប់គ្រាន់ និងកង្វះជាបន្តបន្ទាប់នៃអាជ្ញាធរ បង្អាញពីការរារាំងក្រុមប្រឹក្សាឃុំ/សង្កាត់ពីភាពធ្វើការដោយសកម្ម ក្នុងការសម្រេចឱ្យបានតាមតម្រូវការមូលដ្ឋាន សំដៅកាត់បន្ថយភាពស្របច្បាប់នៅក្នុងកែវភ្នែករបស់ប្រជាពលរដ្ឋ ធ្វើឱ្យពិបាកដល់ការជានាពីមូលនិធិផ្ទាល់ខ្លួនដែលបានពីប្រភពផ្សេងទៀត បន្តបង្ករឱ្យមានបញ្ហាសមត្ថភាពខ្សោយ និងនាំឱ្យមានការសន្មតថាសេវាកម្មជាច្រើនគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលថ្នាក់ខ្ពស់ជាង។

នេះជាការសំខាន់ដែលក្របខណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន និងកំណែទម្រង់តាមវិស័យមានសង្គតភាពជាមួយនឹងតម្រូវការ និងគោលដៅរបស់ SNDD ហើយត្រូវអនុវត្តនូវជំហាននានាដើម្បីបង្កើនល្បឿនការអនុវត្តទៅតាមការកំណត់នៅក្នុងច្បាប់អង្គការដែលខេត្ត ស្រុក និងឃុំ/សង្កាត់ត្រូវការមុខងារ និងការទទួលខុសត្រូវខាងវិស័យជាក់លាក់។ ទាំងនេះអនុញ្ញាតឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិមានអាណត្តិ និងធនធានច្បាស់ជាងមុនក្នុងការគាំទ្រការបម្រើសេវាកម្មមូលដ្ឋានដោយមានការឆ្លើយតប និងទូលំទូលាយ ជាពិសេសជាការសំខាន់នៅឆ្នាំខាងមុខដែលគោលដៅកំណែទម្រង់នឹងផ្តោតទៅលើថ្នាក់ស្រុក។

ការបង្កើន CSF ទៅដល់ចំនួន GDP ខ្ពស់ជាងនេះ និងការអនុញ្ញាតឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិមានគំនិតច្បាស់អំពីធនធាន ដែលពួកគាត់នឹងគ្រប់គ្រង គឺជាការសំខាន់សម្រាប់ការបំរើសេវាកម្មមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។ គំនិតមួយគឺ ការចាត់ចែងឡើងវិញ ឬការបំបែក CSF ទៅជាមូលនិធិមួយសម្រាប់តែសេវាកម្មសង្គម ដែលធនធានរួមបញ្ចូលបានពីក្រសួងមួយចំនួនដែលផ្តល់មូលនិធិនេះ។ ទាំងនេះអាចដោះស្រាយបញ្ហាលិខិតបទដ្ឋានដែលមិនច្បាស់លាស់ចំពោះការប្រើប្រាស់ និងធានាថាការប្រើប្រាស់ CSF ឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានទាំងអស់ជាជាងត្រឹមតែប្រើប្រាស់សម្រាប់តម្រូវការសេដ្ឋកិច្ចតាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ លិខិតបទដ្ឋានដែលអនុញ្ញាតឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិប្រមូលពន្ធខ្នាតតូច ធ្វើឱ្យថ្លៃសេវាដែលប្រមូលបច្ចុប្បន្ននេះក្លាយជាស្របច្បាប់ និងបង្កើនការប្រើប្រាស់ថ្លៃសេវារបស់អ្នកប្រើប្រាស់សម្រាប់សេវាកម្មជាក់លាក់ ក៏អនុញ្ញាតឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិមាននូវហិរញ្ញវត្ថុ និងស្វយ័ភាពច្រើនជាងមុន។

ភាពខុសប្លែកគ្នារវាងលទ្ធភាព និងសមត្ថភាពរបស់ឃុំ/សង្កាត់ក្នុងការប្រមូលចំណូលរៀងខ្លួនគួរតែត្រូវបានកំនត់ និងត្រូវមានភាពបត់បែន ហើយនៅក្នុងលិខិតបទដ្ឋានត្រូវឱ្យមានប្រាក់ ចំណាយ

សម្រាប់បញ្ហានេះ ដោយមានការបណ្តុះបណ្តាលលើបរិបទជាក់លាក់មួយ និង ដោយមានការប្រឹងប្រែងដើម្បីធានាពីការអនុវត្តល្អបំផុតតាមរយៈវេទិកាមូលដ្ឋានឬទស្សនកិច្ចសិក្សា។ ជាចុងក្រោយ ព័ត៌មានអំពីវិធាន និងការអនុវត្តវិមជ្ឈការត្រូវផ្សព្វផ្សាយយ៉ាង ម៉ត់ចត់ជាងនេះទៅដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងប្រជាពលរដ្ឋ។ សភាគឺជា "ជើងឯក" ដ៏មានសក្តានុពល នៃកំណែទម្រង់ និងអាចដើរតួយ៉ាងសំខាន់ក្នុងការកែតម្រង់ភាពយល់ច្រឡំអំពីកំណែទម្រង់ SNDD តាមរយៈវេទិកាថ្នាក់មូលដ្ឋានជាប្រចាំ ដោយស្តាប់ពីក្តីបារម្ភរបស់ប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាទាំងនេះជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ និងដាក់បញ្ចូលតម្រូវការ និងបញ្ហារួមរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ទៅក្នុងដំណើរការអភិវឌ្ឍគោលនយោបាយជាតិ។

## I: សេចក្តីផ្តើម

ការផ្លាស់ប្តូរនយោបាយរបស់កម្ពុជា និងរចនាសម្ព័ន្ធរដ្ឋបាលតាមរយៈកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(SNDD) របស់រាជរដ្ឋាភិបាលកម្ពុជា គឺនៅមានលក្ខណៈថ្មីថ្មោងនៅឡើយ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ឆ្នាំ២០០២ បានបញ្ចូល ការបោះឆ្នោតដោយផ្ទាល់ជ្រើសរើស ក្រុមប្រឹក្សាឲ្យទទួលបន្ទុកក្នុងការបង្កើតផែនការអភិវឌ្ឍន៍សម្រាប់ដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈដំណើរការដែលមានការចូលរួម និង ត្រូវមានអំណាចធន្ទានុសិទ្ធិដើម្បីអនុវត្តគម្រោងដែលឆ្លើយតបទៅនឹងតម្រូវការដែលបានលើក ឡើងក្នុងផែនការទាំងនេះ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឆ្នាំ២០០៨(ច្បាប់អង្គការ) បានកំណត់ឲ្យមានការបោះឆ្នោតដោយប្រយោល ឬអសកល ដើម្បីជ្រើសរើសក្រុម ប្រឹក្សានៅថ្នាក់ខេត្ត និងថ្នាក់ស្រុកដែលជាការចាប់ផ្តើមនូវដំណើរការនៃការរៀបចំ និងការចង្អុលបង្ហាញអំពីមុខងារ និង ធនធានសារពើពន្ធដែលត្រូវប្រគល់ ឬផ្ទេរទៅឲ្យអាជ្ញាធរ ថ្នាក់ក្រោមជាតិ(SNAs) និងបានកំណត់អំពីទំនាក់ទំនងរវាងខេត្តទាំង២៤ ស្រុក ក្រុង និងខណ្ឌទាំង១៩៣ និងឃុំ-សង្កាត់ ទាំង ១៦៣៣ (ដែលតនេះ ហៅកាត់ថាឃុំ) ក្នុងប្រទេស កម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា(RGC) បានកំណត់ថាគោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (នាពេលថ្មីៗនេះ គេហៅថា SNDD) គឺដើម្បី:

- ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការទទួលខុសត្រូវឱ្យកាន់តែ មានភាពស៊ីជម្រៅ
- លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និង
- ផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាឃុំដើម្បីជួយដល់រដ្ឋាភិបាលសំដៅកាត់បន្ថយភាពក្រីក្រ និងភាពខ្វះខាតនៅតាមជនបទប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព។

ក្នុងនីតិកាលទី៤នៃរដ្ឋសភា គោលបំណងគន្លឹះរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
គឺដើម្បីលើកកម្ពស់ការផ្តល់សេវានៅមូលដ្ឋានឲ្យឆ្លើយតបទៅនឹងតម្រូវការសង្គម រូបវន្តនិងសេដ្ឋកិច្ចរបស់បុគ្គល និងក្រុមគ្រួសារ។ ការផ្តោតលើការកំណែទម្រង់បច្ចុប្បន្នគឺនៅថ្នាក់ ស្រុក/ក្រុង និងផ្តោតលើការលើកកម្ពស់ការផ្តល់សេវាដែលអាចសម្រេចបាននូវមាត្រដ្ឋានសេដ្ឋកិច្ច នៅតាមទីកន្លែងដែលមានតម្រូវការរួមនៅទូទាំងឃុំ។ នៅពេលដែលប្រជាពលរដ្ឋអាចចូលរួមក្នុងការធ្វើផែនការ និងការចាត់ចែងធនធាន មានន័យថាវាអាចលើកកម្ពស់នូវការឆ្លើយតបបានត្រឹមត្រូវ មានប្រសិទ្ធផល និងចំគោលដៅនៃការផ្តល់សេវានៅមូលដ្ឋាន ដែលជាការជួយដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់សេវាដែលដោះស្រាយបាននូវតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ និងការស្តែងឲ្យឃើញអំពីភាពក្រីក្រនៅតាមតំបន់ ខុសៗគ្នា។ សរុបមក នៅពេលដែលរដ្ឋាភិបាលកាន់តែខិតជិតប្រជាជន គឺនាំឲ្យមានការលើកកម្ពស់គណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន និងមានការចូលរួមរបស់មូលដ្ឋានកាន់តែខ្លាំងក្លាដែលនេះជាការជួយជម្រុញវប្បធម៌ប្រជាធិបតេយ្យ និង"ការអភិវឌ្ឍន៍ពីថ្នាក់មូលដ្ឋាន"។

ការបែងចែកមុខងារ និងធនធានដល់អាជ្ញាធរថ្នាក់ក្រោមជាតិគឺមានសារៈសំខាន់ណាស់សម្រាប់ដំណើរការនេះក្នុងការបំពេញការងារ។ ថ្នាក់ឃុំមានភារកិច្ចដោះស្រាយបញ្ហាសេដ្ឋកិច្ចនៅមូលដ្ឋាន និងការអភិវឌ្ឍន៍សង្គមដោយប្រជាពលរដ្ឋចូលរួមផ្តល់មតិយោបល់អំពីតម្រូវការរបស់ខ្លួនសម្រាប់ សេវាដែលខ្លួនត្រូវការតាមរយៈផែនការអភិវឌ្ឍន៍ឃុំសម្រាប់រយៈពេល៥ឆ្នាំ(CDP) និងកម្មវិធីវិនិយោគឃុំប្រចាំឆ្នាំ (CIP)។ តាមរយៈកំណែ ទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ វិមជ្ឈការសារពើពន្ធត្រូវបានដោះស្រាយតាមរយៈការផ្ទេរពីថ្នាក់កណ្តាលក្រោមរូបភាពមូលនិធិឃុំ/សង្កាត់(CSF) ដែលបានបានបែងចែកដល់គ្រប់ឃុំនៅទូទាំងប្រទេសដើម្បីឆ្លើយតបទៅនឹង តម្រូវការអាទិភាពសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗដូចបានរៀបរាប់នៅក្នុងកម្មវិធីវិនិយោគឃុំប្រចាំឆ្នាំ។ តម្រូវការទាំងនេះក៏អាចត្រូវបានឆ្លើយតបដោយអ្នកផ្តល់សេវាផ្សេងៗ ទៀតតាមរយៈសិក្ខាសាលា

សមាហរណកម្មថ្នាក់ស្រុក(DIW) ដែលជាការធ្វើសមាហរណកម្មដំណើរការធ្វើផែនការសម្រាប់ឃុំ និងមន្ទីរខេត្តខ្សែបណ្ដាយ ហើយក៏អនុញ្ញាតឲ្យឃុំមានលទ្ធភាពស្វែងរកមូលនិធិពីអ្នកផ្ដល់សេវា ផ្សេងទៀត ដូចជាអង្គការក្រៅរដ្ឋាភិបាល(NGOs) ការផ្ដល់នូវគំនិតយោបល់ដល់ពួកគេអំពីធនធានដែលអាច ប្រើប្រាស់បាន និងប្រភេទនៃគម្រោងដែលអាចទទួលបានមូលនិធិមុនពេលបែងចែកមូលនិធិឃុំ/សង្កាត់។ ប្រសិនបើអ្នកដែលផ្ដល់សេវាមានចំណាប់អារម្មណ៍ក្នុងការផ្ដល់មូលនិធិដល់គម្រោងណាមួយរបស់ឃុំ តាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ពួកគេអាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងបណ្ដោះអាសន្ន(TA)ជាមួយ ឃុំនោះតែម្ដង។

ដំណាក់កាលបន្ទាប់នៃវិមជ្ឈការហិរញ្ញវត្ថុ នឹងពាក់ព័ន្ធដល់ការបែងចែកមូលនិធិដល់ថ្នាក់ ស្រុក/ក្រុង ការផ្ដល់ថវិកាលើកដំបូងសម្រាប់មូលនិធិនេះគឺបានគ្រោងផ្ដល់ជូនសម្រាប់ឆ្នាំ២០១៣។ នាពេលបច្ចុប្បន្ននេះ ក្រសួងខ្សែបណ្ដាយ និងស្ថាប័នជាតិនានា កំពុងធ្វើការពិភាក្សាគ្នាអំពីមុខងារដែលនឹងត្រូវប្រគល់ដល់ថ្នាក់ ស្រុក។ គោលបំណងគឺដើម្បីផ្ដល់ឲ្យស្រុកមានមុខងារ ធនធាន និង អំណាចក្នុងការផ្ដល់សេវាដែលដោះស្រាយដល់តម្រូវការរួមនៅទូទាំងឃុំ និងផ្សាភ្ជាប់ការផ្ដល់សេវាថ្នាក់ស្រុកឲ្យកាន់តែខិតជិតទៅនឹងការផ្ដល់សេវាដោយថ្នាក់ជាតិ និងក្រសួងខ្សែបណ្ដាយ។ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលគាំទ្រដល់ការផ្លាស់ប្ដូរ ទាំងនេះរួមមាន ច្បាប់អង្គការ កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រេចបានជោគជ័យជាច្រើនក្នុងរយៈពេលដ៏ខ្លីកន្លងមកនេះ។ ការបោះឆ្នោតនៅថ្នាក់មូលដ្ឋានបាននាំមកនូវស្ថេរភាព ដោយគ្រប់ស្ថាប័ននយោបាយទាំងអស់បានបំពេញការងារជាមួយគ្នាដើម្បីបម្រើប្រជាជន ហើយជំនឿចិត្តក៏ត្រូវបានកសាងឡើងរវាងអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ តាមរយៈកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រង ការរៀបចំ និងការអនុវត្តគម្រោង នានានៅមូលដ្ឋាន។ ថវិកាសម្រាប់ថ្នាក់ឃុំបានកើនដល់ ២០០លានដុល្លា ហើយសមត្ថភាពក្នុងការគ្រប់គ្រង ហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹងតាមរយៈគោលការណ៍ "ការសិក្សាតាមរយៈការអនុវត្តជាក់ស្ដែង"។ ក៏ប៉ុន្តែកំណែទម្រង់គឺស្ថិតនៅក្នុងដំណាក់ដំបូងនៅឡើយទេ ហើយដើម្បីទទួលបានវិមជ្ឈការសារពើពន្ធដែលកាន់តែទូលំទូលាយ និងកាន់តែមានប្រសិទ្ធភាពដែលអាចសម្រេចបានតាមគោលបំណងរបស់រាជរដ្ឋាភិបាលសម្រាប់ ការអភិវឌ្ឍន៍តាមបែបប្រជាធិប

តេយ្យនៅថ្នាក់ក្រោមជាតិ មានល័ក្ខខ័ណ្ឌគន្លឹះមួយចំនួនដែលទទួលបានពី ពិសោធន៍នៃការអនុវត្ត ល្អប្រសើរជាអន្តរជាតិ[1] ដែលចាំបាច់ត្រូវធ្វើការដោះស្រាយក្នុងដំណាក់កាលបន្ទាប់ទៀតនៃកំណែទម្រង់ដែលជាគោលដៅ នៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរនៅថ្នាក់ស្រុក។

- **ប្រព័ន្ធរដ្ឋបាលសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវតែមានការសម្រប សម្រួលឲ្យបានល្អជាមួយនិងការគាំទ្រច្បាស់លាស់សម្រាប់កំណែទម្រង់នេះ។** ត្រូវតែមានទស្សនៈវិស័យគោលនយោបាយច្បាស់លាស់ និងទូលំទូលាយមួយសម្រាប់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលមានការសម្របសម្រួលបានល្អទាំងគោលនយោបាយរបស់ក្រសួងថ្នាក់ជាតិក្នុងវិស័យផ្សេងៗ ជាមួយនិងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្សេងៗ ។ ក្រសួងថ្នាក់ជាតិត្រូវមានទស្សនវិស័យរួមរយៈពេលវែងសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងចង្អុលបង្ហាញអំពី មុខងារ និងធនធានភ្ជាប់មកជាមួយដែលអាចអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលនៅថ្នាក់មូលដ្ឋាន។ បញ្ហាទាំងនេះត្រូវតែចែងឲ្យបានច្បាស់លាស់នៅក្នុងច្បាប់។

- **ស្វ័យភាពសម្រាប់អាជ្ញាធរថ្នាក់ក្រោមជាតិ។** អាជ្ញាធរថ្នាក់ក្រោមជាតិត្រូវតែមានសមត្ថភាព និងជំនឿចិត្តដើម្បីអនុវត្តសកម្មភាពដោយឯករាជ្យដោយពុំមានការអន្តរាគមន៍ និងការត្រួតពិនិត្យច្រើនពេកពីថ្នាក់លើ។ បញ្ហានេះទាមទារឲ្យមានភារកិច្ចច្បាស់លាស់ និងធនធានគ្រប់គ្រាន់ដើម្បីលើកផែនការ និងរៀបចំថវិកាសម្រាប់សកម្មភាព និងសេវាកម្មដែលអាចឆ្លើយតបនូវរាល់តម្រូវការផ្សេងៗរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

- **ហិរញ្ញវត្ថុគួរអនុវត្តតាមមុខងារ។** សមត្ថភាពមានកម្រិត និងលក្ខណៈនៃការខិតខំ ប្រឹងប្រែងស្តារឡើងវិញក្នុងទសវត្សឆ្នាំ១៩៩០នៅកម្ពុជា មានន័យថាឃុំត្រូវបានផ្តល់ឲ្យនូវមូលនិធិធន្ទានុសិទ្ធិតិចតួច ដើម្បីសាកល្បងលើការផ្តល់សេវា និងកសាងសមត្ថភាពមូលដ្ឋានមុនពេលដែលបែងចែក មុខងារជាក់លាក់មួយចំនួន ដល់ពួកគេ។ នេះគឺជាវិធីសាស្ត្រមួយដ៏មាន ប្រសិទ្ធភាពក្នុងពេលនោះ ក៏ប៉ុន្តែនៅពេលកំណែទម្រង់ដំណើរការទៅ មុខងារសម្រាប់អាជ្ញាធ រថ្នាក់ក្រោម

[1] ល័ក្ខខ័ណ្ឌដែលសមស្របទៅនឹងកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅកម្ពុជា យកចេញពី: Bahl, R (ឆ្នាំ១៩៩៩)។ ការអនុវត្តច្បាប់សម្រាប់វិមជ្ឈការសារពើពន្ធ។ ឯកសារការងារកម្មវិធីសិក្សាអន្តរជាតិ លេខ ៣០។

ជាតិគួរតែបញ្ជាក់ឲ្យបានច្បាស់លាស់មុនពេល ដែលធនធានកាន់តែច្រើន ត្រូវបានផ្ទេរទៅឲ្យពួកគេ ដើម្បីឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិ ដឹងច្បាស់ថាពួកគេអាចប្រើប្រាស់ ធនធាននោះបាន ហើយប្រជាពលរដ្ឋអាច តម្រូវឲ្យឃុំ អនុវត្តការងារ ប្រកបដោយភាព ទទួលខុសត្រូវបានត្រឹមត្រូវ។

- **សមត្ថភាពគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ។** ជាការសំខាន់ណាស់ ដែលមុខតំណែងរបស់បុគ្គលិកនៅថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍន៍សមត្ថភាពត្រូវបានដោះស្រាយ ដើម្បីឲ្យអាជ្ញាធរថ្នាក់ ក្រោមជាតិទទួលបានធនធានមនុស្ស ក៏ដូចជាធនធានហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងការទទួលខុសត្រូវថ្មីរបស់ខ្លួន។ អាជ្ញាធរមូលដ្ឋានចាំបាច់ត្រូវមាន សមត្ថភាពលើជំនាញ ដូចជា គណនេយ្យ ការរៀបចំ ថវិកា រតនាគារ រដ្ឋបាលពន្ធដារ ការគ្រប់គ្រងទិន្នន័យ និងការវាយតម្លៃគម្រោង។

- **ភាពបត់បែនក្នុងច្បាប់ និងបទបញ្ញត្តិនានា។** អាជ្ញាធរថ្នាក់ក្រោមជាតិមានសមត្ថភាពខុសគ្នាៗ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់សេវា ដែលបញ្ហានេះគួរតែមានការយកចិត្តទុកដាក់ពិចារណា នៅពេលដែលមានការផ្តល់ ការទទួលខុសត្រូវលើ ចំណូល និងចំណាយ។ ឧទាហរណ៍ៈ តាមតំបន់ទី ក្រុង ឬទីប្រជុំជនអាចមានសមត្ថភាពខ្ពស់ជាងតំបន់ជនបទក្នុងការបង្កើនចំណូលមូលដ្ឋាន ដូចនេះ ជំនួយពីរដ្ឋបាល ថ្នាក់កណ្តាលគឺកាន់តែ មានសារៈសំខាន់។ ភាពបត់បែន និងការរៀបចំទៅតាម លំដាប់លំដោយនៃកំណែទម្រង់គឺមានសារៈសំខាន់ណាស់ដើម្បីឲ្យមានការផ្លាស់ប្តូរក្នុងច្បាប់ គោលនយោបាយ និងការអនុវត្ត ដោយសារតែអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវបង្កើនសមត្ថភាពឲ្យកាន់តែប្រសើរឡើង ហើយស្ថានភាពការអភិវឌ្ឍន៍នៅមូលដ្ឋានផ្លាស់ប្តូរទៅតាមតំបន់ខុសៗគ្នានៅទូទាំងប្រទេស។

- **សិទ្ធិអំណាចក្នុងការប្រមូលចំណូលរបស់ថ្នាក់មូលដ្ឋាន។** ការប្រមូលចំណូលនៅមូលដ្ឋានធ្វើឲ្យអាជ្ញាធរមូលដ្ឋានមានថវិកាកាន់តែរឹងមាំ ក្នុងការអនុវត្តកម្មវិធីមូលដ្ឋាន។ នេះក៏ជាការលើកកម្ពស់គណនេយ្យ ភាពនៅមូលដ្ឋានផងដែរ ដោយសារតែនៅពេលដែលប្រជាពលរដ្ឋត្រូវបានយកពន្ធ ឬបង់ប្រាក់ក្នុងចំនួនតិចតួច សម្រាប់សេវាណាមួយនោះ ប្រជាពលរដ្ឋ នឹងមាន

ចំណាប់អារម្មណ៍កាន់តែខ្លាំងឡើង ក្នុងការត្រួតពិនិត្យមើលថា តើប្រាក់របស់ពួកគេត្រូវបាន ប្រើប្រាស់ដោយរបៀបណា។

- **រដ្ឋាភិបាលថ្នាក់កណ្ដាលត្រូវតែធ្វើច្បាប់ដែលមានលក្ខណៈច្បាស់លាស់ និងមានស្ថេរភាព ហើយអាច យល់បានពីសំណាក់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ។** ភារកិច្ចត្រូវតែមាន ស្ថេរភាព និងអាចសម្រេចបាន ហើយធនធានហិរញ្ញវត្ថុគួរតែមានលក្ខណៈសាមញ្ញ និងមាន ការណែនាំច្បាស់លាស់ចំពោះ ការប្រើប្រាស់ធនធានទាំងនោះ។ ប្រជាពលរដ្ឋគួរតែដឹងអំពីអ្វី ដែលខ្លួន នឹងបានទទួលពីអាជ្ញាធរមូលដ្ឋាន តាមរយៈ ផ្ដល់ព័ត៌មានប្រកបដោយតម្លាភាពអំពី ការអនុវត្តការងារ និងព័ត៌មានអំពីបែបបទនៃធនធានមូលដ្ឋាន ដែលបានចំណាយ ដែលគួរ តែត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

## II:ចាត់ចែងមូលនិធិបច្ចុប្បន្នដើម្បីបំពេញអាណត្តិរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ

តាមរយៈផែនការអនុវត្តបីឆ្នាំដំបូង(IP3) សម្រាប់កម្មវិធីជាតិ ដើម្បីការអភិវឌ្ឍន៍តាមបែប ប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិឆ្នាំ២០១០-២០១៩(NP-NCDD) ១៣%នៃមូលនិធិសរុប (៣៨.៤ លានដុល្លារនៃមូលនិធិ សរុប ៥០៦លានដុល្លារ) នឹងត្រូវបានផ្ដល់ជូន ដល់ឃុំសម្រាប់ការ វិនិយោគ ដែលគិតជាទឹកប្រាក់ គឺមានចំនួន ប្រមាណ ២៤០០០ដុល្លារ សម្រាប់ឃុំនីមួយៗ និងមាន ការកែសម្រួលខ្លះៗ ដោយផ្អែកតាមប្រជាពលរដ្ឋក្នុង ឃុំ (៤០%) និងសន្ទស្សន៍នៃភាពក្រីក្រ (២០%) ហើយ៤០% ដែលនៅសល់នឹងចែកជូនស្មើៗគ្នា។ ប៉ុន្តែ បើតាមការវិភាគលើច្បាប់ស្ដីពីថវិការ ជាតិប្រចាំឆ្នាំពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១០ បង្ហាញថាការរៀបចំសារពើពន្ធ អន្តររដ្ឋបាលសរុបមិនទាន់ បានកែប្រែច្រើននៅឡើយទេ ដោយក្នុងនោះការបែងចែកទៅឲ្យបណ្ដាខេត្ត ឃុំ និង មន្ទីរខ្សែបណ្ដោយ មានប្រមាណត្រឹមតែ២០%ប៉ុណ្ណោះ នៃការចំណាយសរុបរបស់ជាតិ។ ទោះបីជាថវិកា មាន សារៈសំខាន់ សម្រាប់ការផ្ដល់ជាគំនិតយោបល់អំពីធនធានសរុប ដែលអាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវផ្ដល់សេវា ប៉ុន្តែវាមិនជាមែនជាការព្យាករណ៍ឲ្យត្រឹមត្រូវអំពីចំនួន និងគុណភាពនៃការផ្ដល់សេវា នោះទេ។ ជាងនេះទៀត នាពេលបច្ចុប្បន្ននេះវាពិតជាមានការលំបាកណាស់ ក្នុងការផ្ដល់មូលនិធិ ទៅឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិ តាមប្រព័ន្ធបច្ចុប្បន្ននេះ និងពុំមានទិន្នន័យសម្រាប់ផ្សព្វផ្សាយជា

សាធារណៈអំពីការចំណាយដោយបណ្តា ក្រសួងនានានៅតាមកម្រិតផ្សេងៗ។ តម្លាភាពថវិកាកាន់តែប្រសើរ គឺមានសារៈសំខាន់ណាស់ ក្នុងការវាយតម្លៃ ឲ្យបានត្រឹមត្រូវអំពីវិធីសាស្ត្រនៃការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ និងការផ្តល់សេវាមូលដ្ឋានអាចត្រូវបានលើកកម្ពស់។

ឃុំ/សង្កាត់ត្រូវការហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតួនាទីចេញសេចក្តីសម្រេច តួនាទីប្រតិបត្តិ និងតួនាទីត្រួតពិនិត្យរបស់ខ្លួន។ ឃុំ/សង្កាត់ត្រូវបានផ្តល់ភារកិច្ចឲ្យបង្កើតថវិកាផ្ទាល់ខ្លួនដើម្បីផ្តល់សេវាដែល លើកកម្ពស់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច និងធ្វើឲ្យកាន់តែប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងតំបន់របស់ខ្លួន។ ព័ត៌មានអំពីប្រភពនៃមូលនិធិ និងគម្រោងដែលបានកំណត់ក្នុងកម្មវិធីវិនិយោគឃុំដែលពួក គេបានប្រើប្រាស់គួរត្រូវផ្សព្វផ្សាយជាសាធារណៈតាមរយៈកិច្ចប្រជុំជាប្រចាំនៅតាមភូមិ និងថ្នាក់ឃុំ ឬនៅទីស្នាក់ ការឃុំ។ បច្ចុប្បន្ននេះ ការផ្តល់មូលនិធិដល់ថ្នាក់ឃុំបានមកពីប្រភពផ្សេងៗគ្នាមួយចំនួនៈ

- **ចំណូលពីក្រសួងខ្សែបណ្តោយៈ** ចំណូលទូទៅ និងកម្ចីអន្តរជាតិដែលបានទទួលតាមរយៈរដ្ឋាភិបាល ថ្នាក់កណ្តាលដែលបានបែងចែកដល់ក្រសួងខ្សែបណ្តោយនៅតាមបណ្តាខេត្ត និងស្រុកមួយចំនួន។ ថវិកាទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ការចំណាយប្រចាំឆ្នាំជាទៀងទាត់ (ចំណាយចរន្ត) ជាជាង សម្រាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ(ទុនវិនិយោគ) បើទោះបីជាពួកគេអាចចូលរួមពិគ្រោះ យោបល់ជាមួយឃុំ ប៉ុន្តែជាធម្មតាមិនសូវជាបានអនុវត្តបែបនេះទេ។
- **ជំនួយពីអង្គការផ្តល់ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល** សម្រាប់កម្មវិធីដែលអនុវត្តដោយរដ្ឋាភិបាលថ្នាក់កណ្តាល ឬសម្រាប់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ដើម្បីអនុវត្តសកម្មភាពដែលបានស្នើឡើងដោយឃុំ/សង្កាត់ តាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។ ជាទូទៅបញ្ហានេះគឺមានទំហំតិចតួចទេ។ ស្របពេលដែលព័ត៌មានស្តីពីមូលនិធិរបស់អ្នកផ្តល់ជំនួយនៅមានកម្រិតគឺ មានសារៈសំខាន់ណាស់សម្រាប់ការអនុវត្តលើការចំណាយសេវាសង្គមជាធម្មតា និងរក្សាទុកនូវទុនវិនិយោគ។
- **ប្រភពផ្សេងៗទៀត ដូចជាការបរិច្ចាគពីសំណាក់ប្រជាពលរដ្ឋមូលដ្ឋាន និងគណបក្សនយោបាយ។** ប្រភពបែបនេះផ្តល់ហិរញ្ញវត្ថុចំបងលើ ទុនវិនិយោគសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ

ហើយជាទូទៅមិនត្រូវ បានធ្វើសមាហរណកម្មទៅក្នុងដំណើរការនៃការសម្រេចចិត្តរបស់ ឃុំទេ។

- **ប្រភពចំណូលផ្ទាល់ខ្លួន។** ពន្ធសារពើពន្ធដែលបង្កើតឡើងនៅមូលដ្ឋាន ពន្ធមិនមែនសារពើពន្ធ និង ការយកថ្លៃលើសេវាផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ ប៉ុន្តែបច្ចុប្បន្ននេះមានការផ្តល់ឲ្យនូវផ្នែក តិចតួចប៉ុណ្ណោះនៃចំណូលរបស់ឃុំ។
- **មូលនិធិឃុំ/សង្កាត់:** មូលនិធិដែលបានផ្ទេរពីថ្នាក់កណ្តាលតំណាងឲ្យប្រភពចំបងនៃចំណូលដែលបានប្រើប្រាស់សម្រាប់ការចំណាយលើការផ្តល់សេវាដោយឃុំខ្លួនឯង។

ថ្មីៗនេះ បណ្តាស្រុក និងខេត្តក៏ត្រូវបានផ្តល់ឲ្យនូវមូលនិធិផ្ទាល់ផងដែរ តាមរយៈមូលនិធិវិនិយោគខេត្ត(PIF) និងមូលនិធិវិនិយោគស្រុក(DIF)។ ក្នុងឆ្នាំ២០០៩ មូលនិធិសរុបនេះមានចំនួន ២.២៤លាន ដុល្លារ សម្រាប់ថ្នាក់ខេត្ត និង ៧៨០.០០០ ដុល្លារសម្រាប់ថ្នាក់ស្រុក ហើយត្រូវបានប្រើប្រាស់ចំបង សម្រាប់គម្រោងដែលបម្រើដល់ សេចក្តីត្រូវការរបស់ឃុំ/សង្កាត់។ កង្វះខាតនៃការអនុវត្តឲ្យបានពេញលេញនូវ ច្បាប់ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ដែលបានអនុម័តកាលពីខែកក្កដា ឆ្នាំ២០១១ នៅពេលដែលថ្នាក់ខេត្ត និងថ្នាក់ ស្រុកមានមូលនិធិផ្ទាល់ខ្លួនមានន័យថាថវិការបស់ពួកគេគឺ នៅត្រូវបានគ្រប់គ្រងតាមខ្សែបណ្តាយ ដោយថ្នាក់ស្រុកទទួលមូលនិធិតាមរយៈខេត្ត ដែលនេះជាការជះឥទ្ធិពលដល់ស្វ័យភាពរបស់ស្ថាប័ននេះ។

## III: ការសម្របសម្រួល និងការចាត់ចែងមុខងាររវាងថ្នាក់ក្រោមជាតិ និងក្រសួងថ្នាក់ជាតិ

អាជ្ញាធរថ្នាក់ក្រោមជាតិ អាចត្រូវបានផ្តល់ឲ្យនូវការទទួលខុសត្រូវយ៉ាងទូលំទូលាយ សម្រាប់ការអភិវឌ្ឍន៍នៅមូលដ្ឋាន ប៉ុន្តែនៅក្នុងបញ្ហាជាក់ស្តែងជាច្រើនដូចជាការផ្តល់មូលនិធិ សមត្ថភាព និងការរាំងស្ទះពី ថ្នាក់ក្រសួង មានន័យថាពួកគេមិនបានគ្រប់គ្រងសេវាដោយផ្អែកលើទិដ្ឋភាពសំខាន់នៃអភិវឌ្ឍន៍នៅមូលដ្ឋាននោះទេ ដូចជា ការអប់រំ និងសុខភាព ឬក៏គ្រាន់តែត្រូវបានជ្រើសរើស និងការទទួលខុសត្រូវជាលក្ខណៈបុគ្គល ក្នុងវិស័យណាមួយប៉ុណ្ណោះ។ ធនធានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ទៅឲ្យអាជ្ញាធរមូលដ្ឋាន ដើម្បីជួយពួកគេក្នុង ការឆ្លើយតបទៅភារកិច្ចទូទៅរបស់ពួកគេសម្រាប់ការអភិវឌ្ឍន៍នៅមូលដ្ឋាន ដែលអាចឲ្យពួកគេបង្កើតការ អភិវឌ្ឍន៍នៅមូលដ្ឋានដោយខ្លួនឯងដោយផ្អែកលើតម្រូវការដែលបានកំណត់នៅក្នុងកម្មវិធីអភិវឌ្ឍន៍ឃុំ។ ក៏ប៉ុន្តែ ជាការសំខាន់ណាស់សម្រាប់អាជ្ញាធរ

ថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបឲ្យបានទូលំទូលាយទៅនឹងតម្រូវការដែល មុខងារពីបណ្តាក្រសួងត្រូវបានចង្អុលបង្ហាញ និងមុខងារដែលអាចត្រូវបានអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាព និង ប្រសិទ្ធផលនៅថ្នាក់មូលដ្ឋានដែលត្រូវបានប្រគល់ជូនពីថ្នាក់លើមកថ្នាក់មូលដ្ឋាន ដោយភ្ជាប់ជាមួយធនធាន ហិរញ្ញវត្ថុ និងធនធានមនុស្ស។ ហើយករណីនេះក៏ផ្តល់ឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិស្វែងយល់បានច្បាស់លាស់អំពីអ្វី ដែលជាការទទួលខុសត្រូវរបស់ខ្លួនក្នុងវិស័យផ្សេងៗ ដែលធ្វើឲ្យមានលក្ខណៈកាន់តែងាយស្រួលក្នុងការរៀបរាប់អំពីវិធីសាស្ត្រនៃការទទួលខុសត្រូវលើការ ផ្តល់សេវាដោយអាជ្ញាធរថ្នាក់ក្រោមជាតិអាច ត្រូវបានផ្តល់ហិរញ្ញប្បទានជូន និងធ្វើឲ្យអាជ្ញាធរថ្នាក់ក្រោមមានការទទួលខុសត្រូវ។

មុខងារត្រួតពិនិត្យ រួមបញ្ចូលជាមួយ ការវិភាគ លើវិស័យណាមួយ និងការសម្រេចចិត្តដែលមុខងារ និងធនធានភ្ជាប់មកជាមួយគួរត្រូវ បានផ្ទេរ ដល់អាជ្ញាធរថ្នាក់ក្រោមជាតិនៅគ្រប់លំដាប់ថ្នាក់។ ឧទាហរណ៍ៈ នៅក្នុងមុខងារនៃវិស័យអប់រំ ដែលរួម មានការបង្កើតកម្មវិធីសិក្សា ការជួលគ្រូបង្រៀន និងការដេញថ្លៃសំភារៈសិក្សា។ មុខងារត្រូវបាន ផ្តល់ឲ្យដោយឈរលើគោលការណ៍"ឧបត្ថម្ភទុន" ដែលក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រឆ្នាំ២០០៥ ស្តីពី កំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានកំណត់ថា ពួកគេ គួរសម្រេ ចឲ្យបាន "ប្រសិទ្ធភាព និងប្រសិទ្ធផលធំធេងបំផុតនៃការផ្តល់សេវាសាធារណៈ ដោយរដ្ឋបាល ដែលនៅជិតប្រជាពលរដ្ឋបំផុត និងដើម្បីធានានូវគណនេយ្យភាព ជូនដល់ប្រជាពលរដ្ឋ"។ ក្រសួងចាំបាច់ត្រូវចង្អុលបង្ហាញអំពីមុខងារផ្សេងៗ និងវាយតម្លៃថា តើគួររក្សាទុកនៅថ្នាក់កណ្តាល ឬផ្ទេរទៅកម្រិតណាមួយឲ្យបានត្រឹមត្រូវ (ឃុំ ស្រុក ឬខេត្ត) ដោយផ្អែកលើទស្សនៈឧបត្ថម្ភទុន តាមរយៈការផ្តល់អនុសាសន៍ លើបញ្ហាទាំងនេះដល់អង្គភាពសម្របសម្រួលអន្តរក្រសួង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ដើម្បីធ្វើការសម្រេចចិត្តចុងក្រោយ។ ក្នុងប្រទេសកម្ពុជា មុខងារត្រូវបានកំណត់ថាជាកាតព្វកិច្ច (ក្រុមប្រឹក្សាត្រូវតែអនុវត្ត) ឬលើកលែង(ក្រុមប្រឹក្សាអាចជ្រើសរើសដើម្បីអនុវត្ត) បានតែងតាំង (ក្រុមប្រឹក្សា មានសិទ្ធិអំណាចលើគ្រប់ទិដ្ឋភាពទាំងអស់នៃមុខងារបែបនេះ) ឬបានផ្ទេរឲ្យ(ក្រសួងពាក់ព័ន្ធនៅតែមានការ ត្រួតត្រាទាំងស្រុង)។

ការចាត់ចែងមុខងារគឺជានីតិវិធីដែលមានរយៈពេលវែង និងស្មុគស្មាញ ដែលទាមទារឲ្យមានការគាំទ្រខ្លាំងក្លាពីបណ្តាក្រសួងទាំងអស់ និងយន្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ដូចជាក្រុមការងារដែល មកបំពេញការងារជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ រួមមានក្រសួងមហាផ្ទៃ ក្រសួង

ខ្សែបណ្ដោយ និងអង្គការអ្នកផ្ដល់ជំនួយនានា។ បណ្ដាក្រសួងចំនួន១៥ រួមនិងដៃគូអភិវឌ្ឍន៍បានចូលរួមក្នុងក្រុមការងារការអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងសកម្មភាពដើម្បីពង្រឹងការចាត់ចែងមុខងារ បានបន្តមកតាំងពីឆ្នាំ ២០១០មកម្ល៉េះ។ នៅពេលបច្ចុប្បន្ននេះ ការចង្អុលបង្ហាញអំពីមុខងាររបស់ក្រសួងបានកំពុងប្រព្រឹត្តិទៅ ហើយជំហានទី២គឺការវិភាគអំពីមុខងារដែលគួរត្រូវបានផ្ទេរ និងកំណត់នៅក្នុងច្បាប់។ ត្រឹមបំណាច់ឆ្នាំ២០១២នេះ មុខងារទាំងនេះគួរតែត្រូវបានកំណត់សម្រាប់ការអនុវត្តសាកល្បង។ ទោះបីជាយ៉ាងណា មានបញ្ហាជាច្រើន ដែលពាក់ព័ន្ធនឹងការចាត់ចែងមុខងារ និងភារកិច្ចរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលត្រូវតែជំនះឲ្យបាន។

ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់មួយនៃរដ្ឋាភិបាលទាំងមូល និងទាមទារឲ្យមានទស្សនវិស័យរយៈពេលវែង ដែលរួមបញ្ចូលក្រសួងឲ្យបំពេញការងារជាមួយនិងគោលបំណង នៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ច្បាប់អង្គការច្បាប់ឆ្នាំ២០០៨ បង្កើតមុខងារថ្មីៗ មួយចំនួន និងធនធានសារពើពន្ធក្នុងវិស័យផ្សេងៗសម្រាប់អាជ្ញាធរថ្នាក់ក្រោមជាតិ ប៉ុន្តែគ្រាន់តែជាភារកិច្ចទូទៅប៉ុណ្ណោះ។ អាជ្ញាធរថ្នាក់ក្រោមជាតិ មានការទទួលខុសត្រូវទូលំទូលាយសម្រាប់ការអភិវឌ្ឍន៍នៅមូលដ្ឋាន ប៉ុន្តែការទទួលខុសត្រូវតាមផ្លូវច្បាប់ និងការទទួលខុសត្រូវជាក់លាក់ ព្រមទាំងមុខងារនៅមិនទាន់បានកំណត់ ឲ្យបានច្បាស់លាស់នៅឡើយទេ ខណៈពេលដែល អាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវបានរំពឹងថានឹងទទួលបានការគាំទ្រខាងហិរញ្ញវត្ថុសម្រាប់រយៈពេលវែងសម្រាប់ការផ្ដល់សេវា ប៉ុន្តែបណ្ដាក្រសួងនាពេលបច្ចុប្បន្ន ផ្ដោតការយកចិត្តទុកដាក់តែលើគោលដៅ និងគោលនយោបាយរបស់ខ្លួនប៉ុណ្ណោះ។ កំណែទម្រង់តាមវិស័យដូចជាការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ការិយាធិបតេយ្យ ដីធ្លី ការអប់រំ សុខភាព និងធនធានធម្មជាតិ បានប្រពឹត្តិទៅដោយពុំបានសម្របសម្រួលជាមួយ និងកំណែទម្រង់ទូទៅនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនោះទេ ដែលនាំឲ្យមានកង្វះខាតនៃភាពខុសប្លែកគ្នារវាងតម្រូវការខុសៗគ្នានៅតាមតំបន់ទីក្រុង និងជនបទ។ ក្នុងវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន ដូចជាវិស័យសុខភាព វិស័យអប់រំ និងធនធានធម្មជាតិ សេចក្ដីសម្រេច ភាគច្រើនគឺនៅតែ ធ្វើឡើងនៅ ថ្នាក់កណ្ដាល បើទោះបី ជាបណ្ដាក្រសួងមានការិយាល័យ និងមន្ត្រីរបស់ខ្លួននៅថ្នាក់ខេត្ត និងស្រុកក៏ដោយ។ ជាធម្មតានៅតាមទីកន្លែងដែលសេវាត្រូវបានផ្ទេរពីថ្នាក់លើទៅក្រោម អនុវត្តទៅបានតាមរយៈការកំណត់ថវិកាបានត្រឹមត្រូវសម្រាប់រដ្ឋបាលខេត្ត។ ការវិភាគអំពីការចាត់ចែងមុខងារ

ក្នុងប្រទេសកម្ពុជាក៏ជួបឧបសគ្គផងដែរ តាមរយៈកង្វះខាតនៃការផ្សព្វផ្សាយ អំពីការពន្យល់ឲ្យបានពិស្តារអំពី តម្លៃនៃការអនុវត្តមុខងារផ្សេងៗពីសំណាក់ក្រសួងពាក់ព័ន្ធ។

អាជ្ញាធរថ្នាក់ក្រោមជាតិមិនមានថវិកាគ្រប់គ្រាន់នៅឡើយទេ ដើម្បីឆ្លើយតបទៅ នឹងភារកិច្ចរបស់ខ្លួន អាជ្ញាធរថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ននេះថវិកាក្នុងវិស័យ មួយចំនួនគឺ នៅថ្នាក់កណ្តាល និងប្រព្រឹត្តទៅតាមខ្សែបណ្តោយ តាមរយៈក្រសួងខ្សែបណ្តោយ។ នៅពេលដែលការគ្រប់គ្រងហិរញ្ញវត្ថុកាន់តែច្រើន ត្រូវបានអនុវត្តនៅថ្នាក់ខេត្ត/ រាជធានី ជាហេតុធ្វើឲ្យមានការលំបាកដល់ការវាយតម្លៃឃុំក្នុងនាមជាអង្គភាពផ្តល់សេវាដែលបានទទួលសិទ្ធិពេញលេញដែលតម្រូវ ឲ្យមានស្វ័យភាពខាងហិរញ្ញវត្ថុ។ ការច្នៃប្រឌិតថ្មីៗដូចជាគណៈកម្មាធិការសាលារៀន និង គណៈកម្មាធិការ គ្រប់គ្រងការថែទាំសុខភាពនៅថ្នាក់ឃុំ គឺជាជំហានដ៏មានសារៈសំខាន់ឆ្ពោះទៅរកវិមជ្ឈការ ក្នុងវិស័យទាំងនេះ ប៉ុន្តែបើពុំមានមូលនិធិដែលផ្តល់ផលប្រយោជន៍នៃការប្រគល់ឲ្យនូវការទទួលខុសត្រូវដល់ សហគមន៍មូលដ្ឋាន ដើម្បីគ្រប់គ្រងនោះទេ សេវាកម្មទាំងនេះគឺ ប្រាកដជាមានការបាត់បង់ជាក់ជាពុំខាន។ ភារកិច្ចមិនច្បាស់លាស់ ថវិការពុំគ្រប់គ្រាន់ និងបន្ទាប់មកកង្វះខាតសិទ្ធិអំណាច គឺជាកត្តាដែលធ្វើឲ្យក្រុមប្រឹក្សា ឃុំពុំមានភាពសកម្មក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន កាត់បន្ថយភាពត្រឹមត្រូវតាមច្បាប់របស់ពួកគេក្នុងក្រសែភ្នែករបស់ប្រជាពលរដ្ឋ ធ្វើឲ្យមានការលំបាក ដើម្បីធានាបាននូវមូលនិធិផ្ទាល់ខ្លួនរបស់ពួកគេពីប្រភពផ្សេងៗ បញ្ហាកើតមានជាបន្តបន្ទាប់នៃសមត្ថភាពមានកម្រិត និងនាំឲ្យមានការយល់ថាសេវាមួយចំនួនគឺជាការ ទទួលខុស ត្រូវរបស់រដ្ឋបាលថ្នាក់លើ។

សរុបមកផែនការអភិវឌ្ឍន៍ខេត្ត(PDPs) សម្រាប់ការផ្តល់សេវាគ្របដណ្តប់លើសកម្មភាព និង វិស័យផ្សេងៗ ប៉ុន្តែផែនការទាំងនេះត្រូវបានធ្វើសមាហរណកម្មទៅ នឹងមុខងាររបស់រដ្ឋាភិបាលដោយមិនមានប្រសិទ្ធិភាព ហើយការផ្តល់មូលនិធិក៏មិនបានគ្រប់គ្រាន់ដែរ។ មន្ទីរខ្សែបណ្តោយអាចដាក់សំណើសម្រាប់គម្រោងនានា ទៅក្រសួងពាក់ព័ន្ធថ្នាក់ជាតិ ប៉ុន្តែសំណើនេះត្រូវមាននៅក្នុងថវិកាដែលបានស្នើឡើង។ ផែនការអភិវឌ្ឍន៍ ខេត្តចាំបាច់ត្រូវផ្សាភ្ជាប់ទៅនឹងក្រសួង ផ្សេងៗ និងការប្រតិបត្តិរបស់រដ្ឋាភិបាល និងដើម្បីធ្វើសមាហរណកម្មទៅ ក្នុងផែនការខេត្ត និងដំណើរការធ្វើ ថវិកា ដូចដែលបានអនុវត្តជាមួយឃុំ/សង្កាត់។

IV: **មូលនិធិឃុំ/សង្កាត់** ( CSF )

មូលនិធិឃុំ/សង្កាត់រួមមានចំណូលក្នុងស្រុក និងវិភាគទានរបស់ដៃគូអភិវឌ្ឍន៍។ គោលបំណងរបស់មូលនិធិនេះគឺៈ ដើម្បីបង្កើតភាពជាម្ចាស់នៅមូលដ្ឋានលើសកម្មភាពអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយភាពខុសប្លែកគ្នា នៃការអភិវឌ្ឍន៍នៅតាមតំបន់នានា និងដើម្បីផ្តល់ការលើកទឹកចិត្តសម្រាប់ការកសាងសមត្ថភាព។ មូលនិធិ ឃុំ/សង្កាត់ អាចត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលទូទៅ(បច្ចុប្បន្នមានចំនួន ២៩%នៃមូលនិធិ) និងការអភិវឌ្ឍន៍មូលដ្ឋាន (៧១%)។ ការកើនឡើងលើការផ្តល់ប្រាក់វិភាជន៍ដល់មូលនិធិឃុំ/សង្កាត់ បង្ហាញឲ្យឃើញ អំពីឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០០៣ ប្រាក់វិភាជន៍សរុបត្រូវបានកំណត់ត្រឹម២%នៃចំណូលចរន្តរបស់រដ្ឋដោយបានកើនឡើងដល់ ២.៥% ក្នុង ឆ្នាំ២០០៤ ២.៧% ក្នុងឆ្នាំ២០០៨ ២.៧៥% ក្នុងឆ្នាំ២០០៩ និង២.៨% ក្នុងឆ្នាំ២០១០។ មូលនិធិឃុំ/ សង្កាត់ត្រូវបានចាត់ទុកថាជាកត្តាដ៏សំខាន់ក្នុងការកសាងទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ និងហេត្ថារចនាសម្ព័ន្ធដែលបានអភិវឌ្ឍន៍នៅទូទាំងប្រទេស ដែលបានផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជា រាប់លាននាក់ចាប់តាំងពីពេលចាប់ផ្តើមមូលនិធិនេះមក ដោយបានលើកកម្ពស់ភាពជឿជាក់មក លើអាជ្ញាធរមូលដ្ឋាន និងបានពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំឲ្យឆ្លើយតបទៅនឹងភារកិច្ចរបស់ខ្លួន។

ប៉ុន្តែបើទោះបីជាមានការកើនឡើង នូវប្រាក់វិភាជន៍ ក៏មូលនិធិឃុំ/សង្កាត់នៅតែតំណាងសមាមាត្រតូចមួយប៉ុណ្ណោះនៃការចំណាយ លើវិស័យសាធារណៈ (២.៨%នៃការចំណាយចរន្តក្នុងឆ្នាំ២០១០ 0.២៦% នៃGDP ក្នុងឆ្នាំ២០០៧) ហើយក៏នៅតែមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបឲ្យបានពេញលេញទៅ នឹងតម្រូវការរបស់ប្រជាជន និងភារកិច្ចរបស់ឃុំនោះទេ។ ខណៈពេលដែលកាលពីអតីតកាល ធ្លាប់មានបញ្ហាលើការផ្តល់មូលនិធិ មិនបានទៅដល់ថ្នាក់មូលដ្ឋាន ហើយបច្ចុប្បន្នបញ្ហានេះក៏នៅតែកើតមាននៅរៀងរាល់បំណាច់ឆ្នាំនីមួយៗ។ ទោះបីជាយ៉ាងណា ក៏នៅតែមានការផ្ទេរមូលនិធិដែលមិនស៊ីសង្វាក់គ្នាពេញមួយឆ្នាំតែម្តង ដោយពេលខ្លះឃុំ គ្រាន់តែបានទទួលមូលនិធិក្នុងចំនួនយ៉ាងច្រើននៅពេលបំណាច់ឆ្នាំតែប៉ុណ្ណោះ។ កត្តានេះហើយដែលធ្វើឲ្យមាន ការលំបាកក្នុងការធ្វើផែនការសម្រាប់ប្រភេទនៃសេវាជាក់លាក់ណាមួយ ដែលទាមទារមូលនិធិរយៈពេលវែង ដោយសារតែឃុំមិនដឹងថាតើពេលណា ទើបអាចទូទាត់ឲ្យអ្នកម៉ៅការបាន។ ឃុំក៏ត្រូវបានលើកទឹកចិត្តផងដែរឲ្យប្រើប្រាស់មូលនិធិរយៈពេលពេញមួយឆ្នាំ បើទោះបីជាឃុំទាំងនេះមិនអាចមានលទ្ធភាព ឬអាចអនុវត្តទៅបានក៏ដោយ ហើយចំណូលដែលមិនបានចំណាយ

គឺតែងតែវិលទៅឆ្នាំក្រោយដែលកត្តានេះត្រូវទាក់ទង ទៅនឹងសមត្ថភាពផ្សេងៗគ្នារបស់ឃុំដើម្បីដោះស្រាយកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួន។

មូលនិធិឃុំ/សង្កាត់បានដំណើរការយ៉ាងសំខាន់ ក្នុងនាមជាមូលនិធិមួយសម្រាប់ការផ្តល់ហេត្ថារចនាសម្ព័ន្ធខ្នាតតូច។ ការវិភាគលើគម្រោងទិន្នន័យព័ត៌មាន ដែលបានចងក្រងដោយគណៈកម្មាធិការជាតិដើម្បីការ អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD) អំពីការចំណាយតាមរយៈមូលនិធិឃុំ/សង្កាត់ពី ឆ្នាំ២០០៩ ដល់ឆ្នាំ២០១១ ក្នុងខេត្តចំនួន៥[2] បានបង្ហាញថាមានគម្រោងហេត្ថារចនាសម្ព័ន្ធដឹកជញ្ជូនខ្នាតតូច ចំនួន ១២៦៤ ប្រៀបធៀបទៅនឹងគម្រោងវិស័យសង្គមចំនួន៣០។ កត្តានេះ អាចដោយសារតែប្រវត្តិសាស្ត្ររបស់ខ្លួន ដែលធ្លាប់ជាចំណែក នៃការខិតខំស្តារឡើងវិញនូវហេត្ថារចនាសម្ព័ន្ធ ក្រោយសង្គ្រាមក្នុងទសវត្សឆ្នាំ ១៩៩០ ឬក៏ដោយសារតែការបន្តភ័ន្តច្រឡំពាក់ព័ន្ធនឹងវិធីសាស្ត្រដែលអាចប្រើប្រាស់មូលនិធិឃុំ/សង្កាត់បាន។ នៅពេលដែលមូលនិធិឃុំត្រូវបានបង្កើតឡើង មានការបែងចែករវាងការចំណាយចរន្ត និងការចំណាយវិនិយោគ ទាំងសម្រាប់រដ្ឋបាលទូទៅ និងការអភិវឌ្ឍន៍មូលដ្ឋាន ដែលបានបង្ហាញអំពីតម្រូវការសម្រាប់មូលនិធិឃុំ/ សង្កាត់ដើម្បីចំណាយទាំងហេត្ថារចនាសម្ព័ន្ធថ្មីៗនៅមូលដ្ឋាន និងប្រភេទផ្សេងៗនៃការបន្តសេវាដែលទាមទារឲ្យមាន ការចំណាយចរន្ត។ ទោះបីជាយ៉ាងណាបញ្ហានេះមិនត្រូវបានរាប់បញ្ចូលក្នុងការរៀបចំហិរញ្ញវត្ថុចុងក្រោយទេ ហើយបើទោះបីជាមានការព្យាយាមដោះស្រាយបញ្ហានេះក្នុងច្បាប់ក៏ដោយ ក៏ក្នុងចំណោមក្រុមប្រឹក្សាឃុំនៅតែ អាចមានទស្សនៈយល់ឃើញថា មូលនិធិឃុំ/សង្កាត់ គឺផ្តោតសំខាន់តែលើហេត្ថារចនាសម្ព័ន្ធខ្នាតតូច ហើយមូលនិធិសម្រាប់ប្រភេទសេវាផ្សេងៗ គឺជាករណីលើកលែងរបស់ច្បាប់។ មិនតែប៉ុណ្ណោះ មូលនិធិឃុំ/សង្កាត់គួរ ត្រូវបានបែងចែក មិនលើសពី ១ភាគ៣សម្រាប់រដ្ឋបាល និងមិនគួរតិចជាង២ភាគ៣ឡើយសម្រាប់ការអភិវឌ្ឍន៍ ក៏ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ឃុំ/សង្កាត់ជាច្រើនបែងចែកក្នុងសមាមាត្រប្រហាក់ប្រហែលគ្នា។

## V: **មូលនិធិសម្រាប់ការផ្តល់សេវាតាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក**

ឃុំក៏អាចស្វែងរកមូលនិធិសម្រាប់វិស័យអាទិភាព ក្នុងកម្មវិធីវិនិយោគឃុំផងដែរ តាមរយៈសិក្ខាសាលា សមាហរណកម្មថ្នាក់ស្រុក។ ការវិភាគនៃកម្មវិធីវិនិយោគឃុំក្នុងឆ្នាំ២០០៩ បង្ហាញថា

---

[2] បន្ទាយមានជ័យ កំពង់ធំ កំពត ភ្នំពេញ និងរតនគិរី

ភាគច្រើននៃវិស័យអាទិភាពរបស់ឃុំ (៣៣%) គឺសម្រាប់គម្រោងវិស័យសង្គម (វិស័យសុខាភិបាល អប់រំ ធនធានទឹក និងអនាម័យ)។ កាលពីសិក្ខាសិលាសមាហរណកម្មថ្នាក់ស្រុកឆ្នាំ២០០៨ ៤៧% នៃកិច្ចព្រមព្រៀងបណ្តោះអាសន្នត្រូវ បានចុះហត្ថលេខាលើគម្រោងវិស័យសង្គម ដែលបង្ហាញថា សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកជួយដល់ការ ស្វែងរកមូលនិធិសម្រាប់ការផ្តល់សេវាលើវិស័យផ្សេងៗ ដែលខុសប្លែកពីមូលនិធិឃុំ/សង្កាត់ដែលមូលនិធិនោះ ផ្តោតសំខាន់តែលើសកម្មភាពសេដ្ឋកិច្ចតាមរយៈការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។ ជាទូទៅសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក គឺជាយន្តការល្អមួយសម្រាប់ការផ្តល់មូលនធិ លើតម្រូវការអភិវឌ្ឍន៍របស់ឃុំដែលបាន បង្កើននូវអន្តរកម្មរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងតួអង្គផ្សេងៗទៀតដូចជា មន្ទីរខ្សែបណ្តោយ NGOs និងអ្នកផ្តល់ជំនួយឯកជននានា ដើម្បីជួយដល់ការលើកកម្ពស់គណនេយ្យភាពរបស់តួអង្គទាំងនេះ នៅពេលដែលពួកគេអនុវត្តគម្រោងសេវានៅមូលដ្ឋាន។

ទោះបីជាយ៉ាងណាក៏ដោយ គឺត្រូវទាមទារឲ្យមានមូលនិធិសម្រាប់សកម្មភាព ដែលផ្គត់ផ្គង់បានឆាប់រហ័ស នៅពេលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។ ក្នុងឆ្នាំ២០០៩ កិច្ចព្រមព្រៀងបណ្តោះអាសន្នដែលត្រូវ បានចុះហត្ថលេខាក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក មានត្រឹមតែ ២៣%ប៉ុណ្ណោះ ដែលបានឆ្លើយតប ដោយផ្ទាល់ទៅនឹងអាទិភាពនៃកម្មវិធីវិនិយោគឃុំ ដែលចំនួននេះមានការកើនឡើងបន្តិចបន្តួចបើធៀបទៅនឹង ឆ្នាំ២០០៤ ដែលមានចំនួន ២១% ដែលជាការបង្ហាញឲ្យឃើញថាគម្រោងដែលត្រូវបានផ្តល់និធិឲ្យប្រហែលជា ពុំបានឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាននោះទេ។ កិច្ចព្រមព្រៀងបណ្តោះអាសន្នដែលបានចុះហត្ថលេខា ភាគច្រើនផ្តោតលើវិស័យសង្គមទូទៅច្រើនជាងគម្រោងវិស័យសង្គម ដែលបានស្នើឡើងក្នុងកម្មវិធីវិនិយោគឃុំ ដែលកត្តានេះអាចបង្ហាញថាតួអង្គមួយចំនួនដូចជាក្រសួងខ្សែបណ្តោយ និងNGOs ទំនងជាផ្តល់មូលនិធិតែ លើគម្រោងរបស់ខ្លួនតែប៉ុណ្ណោះលើវិស័យនេះ។ ជាទូទៅ ការអភិវឌ្ឍន៍គោលនយោបាយដោយក្រសួងខ្សែបណ្តោយគឺនៅតែអនុវត្តតាមវិធីសាស្ត្រពីលើចុះក្រោម ដោយពុំមានការផ្តល់យោបល់និងការចូលរួមពីថ្នាក់ក្រោមនោះទេ។ បណ្តាក្រសួងខ្សែបណ្តោយទាំងអស់បានបង្កើតផែនការរបស់ខ្លួនរួចជាស្រេចមុនពេលចូល រួមក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ហើយកត្តាទាំងនេះជានិច្ចកាលគឺអាស្រ័យលើមូលនិធិរបស់អ្នក ផ្តល់ជំនួយដែលអាចប្រើប្រាស់បាន។ ជាធម្មតាឃុំស្នើសុំសេវាផ្សេងៗជាពិសេសវិស័យសង្គមដែលឃុំដឹងថាមន្ទីរខ្សែបណ្តោយ និង NGOs អាចផ្តល់ឲ្យបាន។ ដូច្នេះសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកអាច ឆ្លុះបញ្ចាំងឲ្យឃើញអំពីប្រព័ន្ធនៃការធ្វើផែនការពីលើមក

ក្រោម ដោយផ្សាភ្ជាប់តិចតួចរវាងផែនការចូលរួមនៅមូលដ្ឋាន និងថ្នាក់ជាតិ ព្រមទាំងគោលនយោបាយតាមវិស័យ។ វិស័យអាទិភាពក្នុងកម្មវិធីវិនិយោគឃុំគឺត្រូវបាន ទទួលដោយមន្ទីរខេត្ត បណ្តោយ និងតួអង្គផ្សេងៗ ក្នុងរវាង២សប្តាហ៍មុនតែប៉ុណ្ណោះ ដែលនេះជាពេលវេលាមួយ ដ៏ខ្លីដើម្បីធ្វើសមាហរណកម្ម។ មានកិច្ចការជាច្រើនទៀតដែលយើងចាំបាច់ត្រូវបំពេញឲ្យបាន មុនពេលដែលសិក្ខាសាលសមាហរណកម្មថ្នាក់ស្រុកមកដល់ ដើម្បីឲ្យឃុំស្វែងយល់អំពីប្រភេទនៃធនធានផ្សេងៗដែលអាច ទទួលបានពី NGOs សហគ្រាសឯកជន និងស្ថាប័ននានាដែលអាចមានលទ្ធភាពផ្តល់សេវាដែលឆ្លើយតបទៅ តម្រូវការនៅមូលដ្ឋាន ដូចដែលបានលើកឡើងក្នុងកម្មវិធីឃុំវិនិយោគឃុំ។

## VI: **សមត្ថភាព**

សមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅថ្នាក់ក្រោមជាតិទាំងអស់ គឺស្ថិតក្នុងការអភិវឌ្ឍន៍នៅឡើយ។ កត្តា នេះគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សមត្ថភាពក្នុងការរៀបចំថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុត្រូវបានអភិវឌ្ឍន៍ ដើម្បីឃុំមានលទ្ធភាពឆ្លើយតបទៅ នឹងការទទួលខុសត្រូវលើការផ្តល់សេវារបស់ និងការបំពេញការងារប្រកបដោយឯករាជ្យភាព។ កត្តានេះកើតមានឡើងដោយសារតែបញ្ហាការអប់រំ និងកម្រិតជំនាញទាបនៅថ្នាក់មូលដ្ឋាន។ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំនៅមានកម្រិត ដូចជាអក្សរសាស្ត្រ ការគិតលេខ និងមួយចំនួនខ្វះ ខាតជំនាញបច្ចេកទេស បទពិសោធន៍ និងជំនឿចិត្ត។ការសិក្សាស្តីពីក្រុមប្រឹក្សាឃុំ ដែលបានរៀបចំដោយកម្មវិធី រដ្ឋបាល និងកំណែទម្រង់ (LAAR)របស់អង្គការផេកខេមបូឌា(Pact Cambodia) បង្ហាញថា សមាជិកក្រុមប្រឹក្សាឃុំប្រមាណត្រឹមតែ ៥៨%ប៉ុណ្ណោះដែលមានការសិក្សាត្រឹមថ្នាក់មធ្យមសិក្សា ១៧%បានបញ្ចប់ថ្នាក់បឋមសិក្សា និង២៤% ពុំបានបញ្ចប់ថ្នាក់បឋមសិក្សានោះទេ។ សមាជិកក្រុមប្រឹក្សាឃុំជា ច្រើនមានការទទួលខុសត្រូវផ្សេងៗ ហើយពួកគេតែងតែចំណាយពេលវេលា ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេដោយសារតែប្រាក់បៀវត្សប្រចាំខែរបស់ពួកគេមានចំនួនប្រមាណពី ២០ ទៅ ៣០ដុល្លារ តែប៉ុណ្ណោះ។ បញ្ហានេះហើយ ដែលនាំឲ្យមានការពឹងផ្អែកលើមូលនិធិរបស់អ្នកផ្តល់ជំនួយ ដើម្បីទាក់ទាញបុគ្គលិកដែលមានជំនាញ។ ជាធម្មតាបុគ្គលិកដែល មានជំនាញរដ្ឋបាលបែបវិជ្ជាជីវៈ គឺមានតែស្មៀនឃុំតែប៉ុណ្ណោះ ដែលស្មៀនឃុំនេះត្រូវបានជ្រើសរើសដោយក្រសួងមហាផ្ទៃ។ ប្រការនេះហើយ ដែលជាធម្មតាធ្វើឲ្យស្មៀនមាន តួនាទីដ៏សំខាន់ និងជះឥទ្ធិពលអាក្រក់ដល់ស្វ័យភាពរបស់ក្រុមប្រឹក្សាឃុំ និងគំរាមកំហែងដល់គណនេយ្យភាពពីថ្នាក់លើមកថ្នាក់មូលដ្ឋាន។

ភាពយឺតយ៉ាវនៃការបង្កើតកម្មវិធីវិនិយោគឃុំ ការរៀបចំ និងការឯកភាពលើ ថវិកាព្រមទាំងកង្វះខាត សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំភាគច្រើនក្នុងការបង្កើត កែសម្រួល និងគ្រប់គ្រងថវិកាបណ្ដាលឱ្យមានបញ្ហាដល់ក្រុមប្រឹក្សាឃុំក្នុងការដោះស្រាយការផ្ដល់មូលនិធិ។ ផ្អែកតាមការសិក្សាកាលពីឆ្នាំ២០១១ ដែលធ្វើឡើង ដោយសម្ព័ន្ធភាពជាតិឃុំ/សង្កាត់(NLC/S) បង្ហាញថាមានតែក្រុមប្រឹក្សាឃុំ ១៨%ប៉ុណ្ណោះ ដែលយល់ថាខ្លួនបាន រៀបចំថវិការបស់ខ្លួនបានដោយខ្លួនឯង និង ២៦% បានបញ្ជាក់ថាពួកគេត្រូវការវគ្គបណ្ដុះបណ្ដាលបន្ថែមទៀត ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ។ ការរៀបចំថវិកាសម្រាប់មូលនិធិឃុំ/សង្កាត់ គឺអាស្រ័យលើ សមត្ថភាពមូលដ្ឋានដើម្បី ដោះស្រាយលើបញ្ហាទម្រង់ និងនីតិវិធីដែលតម្រូវដោយក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ(MoEF) ដើម្បីទទួលបានមូលនិធិ។ សម្រាប់ឃុំ/សង្កាត់មួយចំនួនយល់ថា នីតិវិធីទាំងនេះគឺមានភាពស្មុគស្មាញ និងធ្វើឲ្យពួកគេមិនអាចទទួលបានមូលនិធិលើប្រភេទផ្សេងៗ នៃការអន្តរាគមន៍សម្រាប់រយៈវែង ដូចជាវិស័យសង្គម ដែលទាមទារដោយ ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ។

សមត្ថភាពក្រុមប្រឹក្សាឃុំនៅមានកម្រិត ក្នុងការដាក់បញ្ចូលគ្នានូវសំណើ និងផែនការគម្រោងអភិវឌ្ឍន៍។ ទោះបីជាមានការបង្រួមឲ្យកាន់តែខ្លីមកត្រឹម១១ដំណាក់កាល ក៏កម្មវិធីអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំអាច នៅតែមានភាពស្មុគស្មាញសម្រាប់ក្រុមប្រឹក្សាឃុំមួយចំនួនក្នុងការអនុវត្ត។ មិនតែប៉ុណ្ណោះ ការស្វែងយល់បានតិចតួចបំផុតនៅតែកើតមានក្នុងចំណោមឃុំ និងអង្គភាពថ្នាក់លើ ស្ដីពីវិធីសាស្ត្រលើការធ្វើផែនការដើម្បីថែរក្សា និងថ្លៃប្រតិបត្តិការនៃការអនុវត្តគម្រោងបន្ត និងគម្រោងដែលមានរយៈពេលវែង។ កត្តានេះអាចជាករណីដែល រដ្ឋាភិបាល និងក្រសួងថ្នាក់កណ្ដាលជឿជាក់ថាការអនុវត្តឲ្យបានពេញលេញនូវវិមជ្ឈការ គឺគាំទ្រតាមរយៈការបន្តនូវភាពខ្វះខាតសមត្ថភាពគ្រប់គ្រាន់នៅថ្នាក់ឃុំ។ ប៉ុន្តែក្រុមប្រឹក្សាឃុំត្អូញត្អែរថាវគ្គបណ្ដុះបណ្ដាល ដែលទទួលបានពីថ្នាក់កណ្ដាលគឺមិនទាន់គ្រប់គ្រាន់ទេ ទាំងពេលវេលា ភាពទៀងទាត់ និងវិធីសាស្ត្រ ហើយតថភាព ជាក់ស្ដែងគឺក្រុមប្រឹក្សាឃុំបានធ្វើលើសពីសមត្ថភាពរបស់ខ្លួន និងមិនអាចបំពេញបាននូវភារកិច្ចដែលមិនស្រប នឹងភាពជាក់ស្ដែង អាចជាបញ្ហាមួយដ៏ពិតប្រាកដ។

## VII: ប្រភពចំណូលផ្ទាល់ខ្លួន

ភាពចម្រុះនៃប្រភពចំណូលផ្ទាល់ខ្លួន និងការផ្ទេរការគ្រប់គ្រងពីមូលនិធិឃុំ/សង្កាត់ នឹងជួយដល់ឃុំឲ្យ ឆ្លើយតបបានកាន់តែប្រសើរទៅនឹងតម្រូវការនៃសេវាផ្សេងៗរបស់ប្រជាពលរដ្ឋខ្លួន។ នៅក្នុងកម្មវិធីជាតិដើម្បីការ អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានផ្តល់សិទ្ធិដើម្បី "ប្រើប្រាស់សិទ្ធិក្នុងការសម្រេចចិត្ត របស់ពួកគេក្នុងការបង្កើតនូវមូលដ្ឋាន/ឬអត្រានៃប្រភពចំណូលផ្ទាល់ខ្លួនក្នុងអត្រាដែលថ្នាក់ជាតិបានកំណត់"។ ឃុំ មានសិទ្ធិតាមផ្លូវច្បាប់ដើម្បីប្រមូលពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យ និងពន្ធថ្លៃជួល។ កិច្ចពិភាក្សាអំពី បញ្ហានេះគួរតែត្រូវបានធ្វើឡើងមុនពេលដែលមានច្បាប់ ប៉ុន្តែពុំបានធ្វើឡើងឡើយ ហើយនៅក្នុងការអនុវត្តជាក់ស្តែង ឃុំ ប្រមូលចំណូលបានតែថ្លៃរដ្ឋបាលធម្មតាប៉ុណ្ណោះ ដូចជាសំបុត្រកំណើត សំបុតអាពាហ៍ពិពាហ៍ និងសំបុត្រមរណៈភាព។ នាពេលបច្ចុប្បន្ននេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានគ្រប់គ្រងមូលនិធិទាំងអស់ សម្រាប់ថ្នាក់ក្រោមជាតិ ហើយបញ្ហាសម្របសម្រួលរវាងបណ្តាក្រសួងថ្នាក់ជាតិ និងកង្វះការព្រមព្រៀងលើការចាត់ចែងការទទួលខុសត្រូវខាងការយកពន្ធ ធ្វើឲ្យឃុំមិនអាចប្រមូលចំណូលផ្ទាល់របស់ខ្លួន។ សម្រាប់អាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីប្រមូលប្រភពចំណូលផ្ទាល់ខ្លួនឲ្យបានគ្រប់គ្រាន់ ចាំបាច់ ត្រូវតែមានចំណេះដឹងបច្ចេកទេសគ្រប់គ្រាន់ផងដែរ ដោយបណ្តាក្រសួងនានា ត្រូវកំណត់ អំពីពន្ធដារដែលឃុំអាចប្រមូលបាន និងគាំទ្រ សមត្ថភាពដល់ឃុំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីប្រមូលចំណូលនៅមូលដ្ឋាន ស្របតាមយន្តការ ដែលធានាបាននូវគណនេយ្យភាព និងតម្លាភាពនៃការប្រមូលចំណូល។

មូលដ្ឋានចំណូលសាធារណៈនៅកម្ពុជាមានប្រមាណត្រឹមតែ១២%ប៉ុណ្ណោះ នៃ GDP ដែលកត្តានេះ ហើយដែលរាំងដល់ការយកពន្ធ នៅមូលដ្ឋានឲ្យបានទូលំទូលាយ។ ក៏ប៉ុន្តែ ការប្រមូលពន្ធនៅថ្នាក់មូលដ្ឋានក្រៅផ្លូវការកើតមានតាមរយៈពន្ធដា និងថ្លៃសេវាលើការជួញដូរផលិតផល ដូចជាជ័រទឹក និងត្រី ហើយទាំងនេះអាចក្លាយជាការប្រមូលពន្ធផ្លូវការ។ ៧៥%នៃអ្នកឆ្លើយសំណួរ ក្នុងការសិក្សាដែលធ្វើឡើងដោយសម្ព័ន្ធភាពជាតិ ឃុំ/សង្កាត់ស្តីពីក្រុមប្រឹក្សាឃុំ/សង្កាត់ បង្ហាញថាពួកគេគួរតែត្រូវបានប្រមូលចំណូលពន្ធដា និងថ្លៃផ្សេងៗនៅមូលដ្ឋាន ប៉ុន្តែបញ្ហានេះនៅមិនទាន់បានអនុវត្តនៅឡើយទេ។ ឃុំក៏អាចទទួលយកការប្រមូលតិចតួចលើ ថ្លៃសេវាប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ ពីអ្នកលក់ដូរតាមផ្សារ ដែលបច្ចុប្បន្នកំពុងតែអនុវត្តនៅតាមថ្នាក់ស្រុក និងខេត្ត និងបណ្តាអាជីវកម្ម

ធម្មតាមួយចំនួននៅតាមមូលដ្ឋាន[3]។ សរុបមកការយកថ្លៃសេវាតិចតួចពីអ្នកប្រើប្រាស់ លើសេវាកម្មនានា អាចធ្វើឲ្យឃុំមានហិរញ្ញវត្ថុច្រើនជាងមុន និងលើកកម្ពស់ការចូលរួម និងគណនេយ្យភាពនៅមូលដ្ឋានដោយសារតែការចំណាយក្នុងចំនួនតិចតួចសម្រាប់សេវាកម្មនោះ នឹងបង្កើនការលើកទឹកចិត្តដល់ការត្រួតពិនិត្យនៅមូលដ្ឋានថា តើពួកគេផ្តល់សេវាយ៉ាងដូចម្តេច។ ថ្លៃអ្នកប្រើប្រាស់មាននៅក្នុងសេវាកម្ម ជាក់លាក់មួយចំនួនដូចជា ទឹក និងភ្លើង ប៉ុន្តែកត្តានេះអាចត្រូវបានពង្រីកដល់វិស័យ/សេវាកម្មផ្សេងទៀត ដោយមានការធានាបាននូវផលប្រយោជន៍របស់អ្នកក្រីក្របំផុត និងអាចនៅតែទទួលបាននូវសេវាដែលប្រកបដោយ គុណភាពខ្ពស់។

## VIII: កត្តាផ្សេងៗទៀតដែលជះឥទ្ធិពលដល់ភាពជោគជ័យនៃវិមជ្ឈការសារពើពន្ធ

ត្រូវតែមាន **យន្តការគណនេយ្យភាព** ច្បាស់លាស់ និងមានប្រសិទ្ធភាព ក្នុងការអនុវត្តដើម្បីធានាថា អាជ្ញាធរថ្នាក់ក្រោមជាតិទទួលខុសត្រូវ លើការបំពេញការងាររបស់ខ្លួនទៅតាមភារកិច្ចជាក់លាក់ ដូចជាការធ្វើ សេចក្តីសម្រេចចិត្ត និងធនធានដែលពួកគេប្រើប្រាស់ជាដើម។ ច្បាប់អង្គការចែងអំពីទំនាក់ទំនងគណនេយ្យភាព គន្លឹះជាក់លាក់រវាងអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋកម្ពុជា។ ជាធម្មតា គណ នេយ្យភាពមានទិសដៅឆ្ពោះទៅរកថ្នាក់ក្រោមជាតិដែលខ្ពស់ជាង និងបណ្តាក្រសួង និងស្ថាប័នថ្នាក់កណ្តាល ក៏ប៉ុន្តែ អនុលោមតាមច្បាប់ក្រុមប្រឹក្សារបស់អាជ្ញាធរថ្នាក់ក្រោមជាតិគឺ "ការទទួលខុសត្រូវដោយផ្ទាល់ចំពោះ ប្រជាពលរដ្ឋទាំងអស់ចំពោះការធ្វើសេចក្តីសម្រេចចិត្តលើអាទិភាពនានា និងដើម្បីធានាដល់ការអភិវឌ្ឍន៍តាម បែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន" និងមានការទទួលបន្ទុកលើការបង្កើតយុទ្ធសាស្ត្រសម្រាប់បញ្ហា នេះ។ ក្រុមប្រឹក្សាស្រុកមានការទទួលខុសត្រូវទាំងចំពោះក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋចំពោះការធ្វើសេចក្តី សម្រេចចិត្តរបស់ពួកគេ ហើយលទ្ធផលនៃការសម្រេចចិត្តទាំងនោះ ត្រូវទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល កម្ពុជា និងប្រជាពលរដ្ឋ ចំពោះការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ពួកគេត្រូវតែរៀបចំឲ្យមានដំណើរការពិគ្រោះយោបល់ជាមួយសាធារណៈជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានានូវតម្លាភាព ដោយមានការផ្សព្វផ្សាយពេញលេញអំពីឯកសារហិរញ្ញវត្ថុ និងឯកសារគន្លឹះផ្សេងៗ។

---

[3] អាជីវកម្មទាំងនេះរួមមាន អ្នកបើករោងម៉ាស៊ីនកិនស្រូវ អ្នកធ្វើឡឥដ្ឋ អ្នកធ្វើទឹកកក សេវាកម្មស្បៀងអាហារ ហាងលក់គ្រឿងទេស អ្នកលក់គ្រឿងឈើ អាជីវកម្មនានាដែលពាក់ព័ន្ធនឹងធនធានធម្មជាតិ និងអាជីវកម្មសាកអាគុយ។

ក្រុមប្រឹក្សាស្រុកត្រូវតែបំពេញការងារជាមួយក្រុមប្រឹក្សាឃុំ ដើម្បីលើកកម្ពស់ការចូលរួមជាសាធារណៈ និងដើម្បីឆ្លើយតបផងដែរទៅនឹងតម្រូវការ និងសំណើរបស់ក្រុមប្រឹក្សាឃុំ ដូចជាការធ្វើសមាហរណកម្មផែនការ ឃុំទៅក្នុងផែនវិនិយោគ៣ឆ្នាំ និងផែនការអភិវឌ្ឍន៍ស្រុក៥ឆ្នាំ។ នៅពេលដែលស្រុកដឹងថាក្រុមប្រឹក្សាឃុំពុំមាន សមត្ថភាពក្នុងការបំពេញការងារទៅតាមភារកិច្ចនៃអាណត្តិរបស់ខ្លួននោះទេ ពួកគេត្រូវមានការទទួលខុសត្រូវ ក្នុងការរាយការណ៍អំពីបញ្ហានេះជូនទៅក្រសួងមហាផ្ទៃ។ ខណៈពេល ដែលក្រុមប្រឹក្សាត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រយោល ដោយថ្នាក់ក្រោម រីឯគណៈអភិបាលត្រូវបានតែងតាំងដោយក្រសួងមហាផ្ទៃ ពួកគេត្រូវ មានភារកិច្ចលើភាពតំណាងការសម្របសម្រួល និងការចង្អុលបង្ហាញដល់ក្រសួងខ្សែបណ្តោយ និងស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលបំពេញការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានការទទួលខុសត្រូវចំពោះ អង្គភាពទាំងនោះ។ គណៈអភិបាលផ្តល់ប្រឹក្សាយោបល់ដល់ក្រុមប្រឹក្សាក្នុងការបំពេញភារកិច្ចរបស់ខ្លួន ហើយក្រុមប្រឹក្សាអាចត្រួតពិនិត្យលើសកម្មភាពនានារបស់អភិបាល និងគណៈអភិបាល និងអាចចោទសួរពួកគេឲ្យ បំភ្លឺអំពីបញ្ហានានានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

គណនេយ្យភាពទូទៅ និងគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈកាន់តែទូលំទូលាយអាចធ្វើឲ្យអភិបាល កិច្ចមូលដ្ឋានកាន់តែមានភាពល្អប្រសើរ និងការអភិវឌ្ឍន៍កាន់តែរឹងមាំ។ ប៉ុន្តែនៅថ្នាក់មូលដ្ឋានមិនសូវយល់ ពាក្យថា "គណនេយ្យភាព" នោះទេ និងមិនទាន់មានវិសាលភាពគ្រប់គ្រាន់សម្រាប់សង្គមស៊ីវិលដើម្បីដើរតួនាទី ឲ្យបានរឹងមាំក្នុងការជួយដល់ប្រជាពលរដ្ឋឲ្យជឿជាក់ថា អាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវលើការ ចំណាយធនធានផ្សេងៗ។

ដំណើរការនៃការធ្វើផែនការដោយមានការចូលរួម គឺមានសារៈសំខាន់ណាស់ក្នុងការធានាបាននូវគណនេយ្យភាព និង**ការទទួលបានព័ត៌មាន** ដែលធ្វើឲ្យប្រជាពលរដ្ឋកាន់តែជឿជាក់ថាអាជ្ញាធរមូលដ្ឋានមានការទទួលខុសត្រូវ។ បើទោះជាអ្នកភូមិអាចទទួលបានព័ត៌មាន អំពីមូលនិធិឃុំ/សង្កាត់តាមរយៈកិច្ចប្រជុំភូមិ និងឃុំ និងនៅទីស្នាក់ការឃុំក៏ដោយ ក៏នៅតែមានការខ្វះខាតនូវព័ត៌មានចំណេះដឹង និងការស្វែងយល់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មាន ទោះបីជាតថភាពជាក់ស្តែងពេលខ្លះការបង្កើតនូវក្របខ័ណ្ឌច្បាប់មានការវិវត្តន៍។ ការផ្តល់ព័ត៌មានជាសាធារណៈ គឺនៅមានការរីកចំរើនតិចតួចនៅឡើយ ជាពិសេសពាក់ព័ន្ធនឹង ហិរញ្ញវត្ថុសាធារណៈ។ នៅតាមទីកន្លែងមួយចំនួន ប្រជាពលរដ្ឋអាចពុំមានការយល់ដឹងទាល់តែ សោះអំពីតួនាទី និងការទទួលខុសត្រូវរបស់ឃុំ

ហើយនៅក្នុងករណីសិក្សាមួយចំនួនបានបង្ហាញថាប្រជាពលរដ្ឋមិនទាំងដឹងថា ឃុំមានឆន្ទានុសិទ្ធិផ្ទាល់ខ្លួនអ្វីខ្លះផងលើមូលនិធិសម្រាប់ការអភិវឌ្ឍន៍។ កត្តាទាំងនេះកើតមាន ដោយសារតែពុំមានលំហូរព័ត៌មានបានគ្រប់គ្រាន់ពាក់ព័ន្ធនឹងបញ្ហាអភិវឌ្ឍន៍នានាពីថ្នាក់កណ្តាលមកថ្នាក់ឃុំ/សង្កាត់ ដោយសារតែកង្វះខាតក្នុងការឆ្លើយតបលើបញ្ហានៅមូលដ្ឋាន ក្នុងដំណើរការធ្វើគោលនយោបាយ និងកង្វះខាតការចូលរួមពីសង្គមស៊ីវិលក្នុងការស្វែងរកព័ត៌មានពីរដ្ឋាភិបាល និងការផ្សព្វផ្សាយជូនដល់សហគមន៍។

## IX: **សន្និដ្ឋាន**

ដើម្បីធ្វើឲ្យវិមជ្ឈការសារពើពន្ធមានប្រសិទ្ធភាព និងដើម្បីធ្វើឲ្យកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជាឆ្លើយតបទៅនឹងទិសដៅរបស់ខ្លួន ត្រូវតែមានមុខងារគ្រប់គ្រាន់ មុខងារធនធានប្រកបដោយស្ថេរភាព និងមុខងារច្បាស់លាស់ ដូចមានចែងក្នុងច្បាប់ដើម្បីឲ្យអាជ្ញាធរថ្នាក់ក្រោម ជាតិមានលទ្ធភាពបំពេញការងារដោយស្វ័យភាព មន្ត្រីមូលដ្ឋានមានសមត្ថភាពខ្ពស់ដើម្បីដោះស្រាយនីតិវិធី ហិរញ្ញវត្ថុ និងក្របខ័ណ្ឌគោលនយោបាយរឹងមាំ និងមានភាពស៊ីសង្វាក់គ្នារវាងបណ្តាក្រសួងរបស់រដ្ឋាភិបាល និងមន្ទីរជំនាញ ព្រមទាំងធ្វើសមាហរណកម្មតម្រូវការឲ្យមានភាពបត់បែន និងតាមលំដាប់លំដោយ។ ទោះបីជា សម្រេចបានកំណែទម្រង់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក៏ការសម្របសម្រួលដ៏រឹងមាំ នៃប្រព័ន្ធរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រហែលជា តម្រូវដ៏សំខាន់បំផុតសម្រាប់កំណែទម្រង់នាពេលអនាគត។ នៅមានកត្តាជាច្រើនដែលត្រូវសម្រេចឲ្យបានដើម្បីបែងចែកមុខងារឲ្យបានច្បាស់លាស់ពី បណ្តាក្រសួងថ្នាក់ជាតិមកអាជ្ញាធរថ្នាក់ក្រោមជាតិ ស្របតាមការផ្ទេររបស់អន្តររដ្ឋាភិបាលនិងកម្មវិធីកសាងសមត្ថភាព។ ការពន្យាពេលក្នុងការចាត់ចែងមុខងារនៅតាមបណ្តាក្រសួងថ្នាក់កណ្តាល មានន័យថាឃុំ/សង្កាត់នៅតែមានភារកិច្ចមិនច្បាស់លាស់ និងក្នុងករណីមួយចំនួនគឺពួកគេពុំមានជំនឿចិត្ត ដើម្បីប្រើប្រាស់នូវឆន្ទានុសិទ្ធិរបស់ខ្លួន លើមូលនិធិសម្រាប់សេវាផ្សេងៗ ក្រៅតែពីហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនោះទេ។ សមត្ថភាពត្រូវបានលើកកម្ពស់តាមវិធីសាស្ត្រ "ការរៀនសូត្រតាមរយៈការអនុវត្តជាក់ស្តែង" ប៉ុន្តែនៅក្នុងវិស័យ គន្លឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុ គឺនៅតែមានការខ្វះខាតមួយចំនួន និងនៅតែមានការភ័ន្តច្រឡំមួយចំនួនអំពី កំណែទម្រង់ និងការប្រើប្រាស់មូលនិធិឃុំ/សង្កាត់ទាំងក្នុងចំណោមក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ។

វិធីសាស្ត្រដែលសេវាមូលដ្ឋានត្រូវបានផ្តល់មូលនិធិ គឺនៅតែពិបាកដោះស្រាយ។ ការផ្ទេរពីថ្នាក់កណ្តាល មកមូលនិធិឃុំ/សង្កាត់គឺមានសារៈសំខាន់ណាស់ ប៉ុន្តែអាចមានកម្រិតទាបពេកសម្រាប់ឃុំ/សង្កាត់ដើម្បីឆ្លើយ តបទៅនឹងតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន។ នៅពេលដែលសេវាកម្មត្រូវបានផ្តល់មូលនិធិដោយក្រសួងខ្សែបណ្តោយ និងអង្គការផ្សេងៗ ការបែងចែកមុខងារទាំងស្រុងមិនបានពេញលេញដោយក្រសួងថ្នាក់ជាតិ និងកង្វះខាតការសម្របសម្រួលរវាងតួអង្គនានា មុនពេលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកគឺនៅតែជាបញ្ហា។ ការណ៍នេះមិនអាចជួយសម្រួលបានដោយសារតែកង្វះខាតស្វ័យតភាពហិរញ្ញវត្ថុ និងថវិកានៅថ្នាក់ស្រុក ហើយថ្នាក់ខេត្តនៅ តែគ្រប់គ្រងទាំងស្រុង។ អាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ឃុំនៅតែត្រូវការមធ្យោបាយដើម្បី បំពេញការងារដោយឯករាជ្យ និងផ្តល់ហិរញ្ញវត្ថុចំប្រភេទសេវាកម្មដែលអាចយតបទៅនឹងតម្រូវ ការរបស់មូលដ្ឋាន។ កត្តានេះ អាចធ្វើឲ្យមានលក្ខណៈប្រសើរបាន តាមរយៈសកម្មភាពដែលធ្វើឲ្យ អាជ្ញាធរថ្នាក់ក្រោមជាតិប្រមូលចំណូលផ្ទាល់ខ្លួនរបស់ពួកគេជាជាងអ្វីដែលពួកគេកំពុងធ្វើនាពេល បច្ចុប្បន្ននេះ។

## X: **អនុសាសន៍**

- កិច្ចខិតខំប្រឹងប្រែងត្រូវធានាថា ក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងបទបញ្ញត្តិ ព្រមទាំងកំណែទម្រង់តាមវិស័យមានសង្គតភាពជាមួយ នឹងតម្រូវការ និងគោលបំណងនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ជំហាននានាគួរត្រូវបានធ្វើឡើង ដើម្បីពន្លឿនការកំណត់លក្ខខ័ណ្ឌនៅក្នុងច្បាប់អង្គការដែលចែងថា ខេត្ត ស្រុក និងឃុំចាំបាច់ត្រូវការមុខងារ និងការទទួលខុសត្រូវតាមវិស័យជាក់លាក់។ ប្រសិនបើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានដឹកនាំ និងផ្តួចផ្តើមឡើងដោយវិស័យផ្សេងៗគ្នាជាជាងក្រសួងមហាផ្ទៃតែឯង នេះអាចជួយដល់ការសម្របសម្រួលនានា។
- ការអនុញ្ញាតឲ្យឃុំ/សង្កាត់មាន កម្រិតប្រភពធនធានតិចតួច គឺជាវិធីសាស្ត្រដ៏សំខាន់ក្នុងការកសាងសមត្ថភាព និងភាពជឿជាក់ ក្នុងអំឡុងពេលដំណើរការកសាងឡើងវិញក្រោយជម្លោះនៅក្នុងទសវត្សទី៩០ និងនៅក្នុងដំណាក់កាលដំបូងនៃកំណែទម្រង់នៅដើមសតវត្សទី២១នេះ ប៉ុន្តែនាពេលអនាគតលំហូរហិរញ្ញវត្ថុគួរអនុវត្តតាមការចាត់ចែងមុខងារដើម្បីឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិដើរតួដោយឯករាជ្យ និងជឿជាក់ក្នុងការឆ្លើយតបចំពោះតម្រូវការផ្សេងៗរបស់សហគមន៍មូលដ្ឋានទូទាំងប្រទេស ដែលនេះនឹងអនុញ្ញាតឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិមានធនធាន និងអាណត្តិការងារច្បាស់លាស់ក្នុងការគាំទ្រដល់ការផ្តល់សេវាកម្មមូលដ្ឋានឆាប់រហ័ស និងទូលំទូលាយ។

- ដំណាក់កាលបន្ទាប់នៃកំណែទម្រង់គួរផ្តោតលើ ការកំណត់ឲ្យបានច្បាស់លាស់ អំពីមុខងារ ធនធាន និងការទទួលខុសត្រូវរវាងថ្នាក់ស្រុក និងឃុំ។ ស្រុកមានអំណោយផលខ្ពស់ជាងក្នុងការផ្តល់សេវាកម្មជាក់លាក់តាមរយៈ សមត្ថភាពរបស់ខ្លួន ដើម្បីសម្រេចឲ្យបានសេដ្ឋកិច្ចនៃមាត្រដ្ឋាន។ នៅពេលដែលស្ថានភាពនេះអាចអនុវត្តបាន ស្រុកអាចជួយឆ្លើយតបចំពោះអាទិភាពរួមរបស់ឃុំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាមួយនឹង ការត្រួតពិនិត្យរបស់អាជ្ញាធរឃុំ និងសហគមន៍មូលដ្ឋានលើការផ្តល់សេវាកម្មទាំងនេះ។
- ការធ្វើផែនការរបស់មន្ទីរខ្សែបណ្តោយ និងឃុំ គួរត្រូវបានធ្វើសមាហរណកម្មឲ្យកាន់តែស្អិតរមួតពេញមួយឆ្នាំ ខណៈដែលបច្ចុប្បន្នគឺមានពេលវេលាតិចតួចណាស់ ក្នុងការធ្វើសមាហរណកម្មផែនការទាំងនោះមុន ពេលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។ យន្តការនានាក៏គួរត្រូវអភិវឌ្ឍន៍ឡើងដើម្បីផ្សាភ្ជាប់ឲ្យបាន កាន់តែប្រសើរនូវការធ្វើផែនការដែលមានការចូលរួមពីថ្នាក់មូលដ្ឋាន ទៅក្នុងដំណើរការអភិវឌ្ឍន៍គោលនយោបាយជាតិ។
- ការបង្កើនមូលនិធិឃុំ/សង្កាត់ទៅក្នុងចំនួនសមាមាត្រខ្ពស់ជាងមុន នៃផលិតផលក្នុងស្រុកសរុប និងការធានាការផ្តល់ហិរញ្ញវត្ថុគ្រប់គ្រាន់នៃមូលនិធិវិនិយោគស្រុក និងមូលនិធិវិនិយោគខេត្ត គឺចាំបាច់ណាស់។ កម្រិតផ្សេងៗនៃអាជ្ញាធរថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានលទ្ធភាពគ្រប់គ្រងដោយឯករាជ្យលើថវិការបស់ខ្លួន និងមានការយល់ដឹងច្បាស់លាស់អំពីប្រភពធនធានដែលពួកគេនឹងទទួលបាននៅឆ្នាំបន្ទាប់ ដើម្បីធ្វើផែនការដែលមានប្រសិទ្ធភាពក្នុងការឆ្លើយតបចំពោះតម្រូវការមូលដ្ឋាន។
- មូលនិធិឃុំ/សង្កាត់អាចត្រូវបានចាត់ចែងឡើងវិញ ឬបែងចែកទៅជាមូលនិធិសម្រាប់តែសេវាកម្មសង្គមប៉ុណ្ណោះ ជាមួយនឹងប្រភពធនធានដែលបានប្រមូលពីក្រសួងពាក់ព័ន្ធនានា។ ការធ្វើបែបនេះនឹងអាចដោះស្រាយបញ្ហានៃការកំណត់ មិនច្បាស់លាស់អំពីការប្រើប្រាស់មូលនិធិនេះ និងអាចធានាថាការប្រើប្រាស់មូលនិធិឃុំ/សង្កាត់ គឺបានឆ្លើយតបចំពោះរាល់តម្រូវការមូលដ្ឋាន ជាជាងការប្រើប្រាស់តែទៅ លើតម្រូវការផ្នែកសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ខណៈដែលគម្រោងវិស័យសង្គមបច្ចុប្បន្ន គឺភាគច្រើនបានទទួលមូលនិធិតាមរយៈសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក វាក៏អាចធានាថាសេវាកម្មសង្គមទាំងនេះឆ្លើយតបត្រឹមត្រូវជាងចំពោះអាទិភាពនៅក្នុងកម្មវិធីវិនិយោគឃុំ/សង្កាត់ ជាជាងអាទិភាពរបស់តួអង្គផ្សេងទៀត ដូចជា ក្រសួងខ្សែបណ្តោយ និងអង្គការមិនមែនរដ្ឋាភិបាល។

- ព័ត៌មានអំពីប្រភេទនៃការចំណាយដែលអាចមានតាមរយៈមូលនិធិឃុំ/សង្កាត់ គួរត្រូវធ្វើឡើងឲ្យច្បាស់លាស់ជាងនេះសម្រាប់គ្រប់គ្រងឃុំ/សង្កាត់និងប្រជាពលរដ្ឋ ការចំណាយនៅក្នុងកម្រិតឃុំ/សង្កាត់គួរត្រូវមានសង្គតភាពជាងមុន ហើយបទបញ្ញត្តិនិងនីតិវិធីសម្រាប់ការរៀបចំថវិកា និងសម្រាប់ការទទួលមូលនិធិគួរត្រូវធ្វើឲ្យមានលក្ខណៈសាមញ្ញជាងមុន។
- បទបញ្ញត្តិ ដែលអនុញ្ញាតឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិ ប្រមូលពន្ធដែលមានទំហំតូច រៀបចំជាផ្លូវការនូវថ្លៃពន្ធដែលបានប្រមូលបច្ចុប្បន្ន និងលើកកម្ពស់ការប្រើប្រាស់ថ្លៃពន្ធនេះសម្រាប់សេវាកម្មជាក់លាក់ ក៏អាចអនុញ្ញាតឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់គ្រងថវិការបស់ខ្លួនកាន់តែមានប្រសិទ្ធភាព និងធ្វើផែនការរយៈពេលវែងសម្រាប់សេវាកម្មមូលដ្ឋាន។ នេះតម្រូវឲ្យមានការបែងចែកប្រភពចំណូលច្បាស់លាស់ជាងមុន រវាងឃុំនិងខេត្ត ការលុបបំបាត់ភាពស្មួនគ្នានៃដែនសមត្ថកិច្ចប្រមូលចំណូល និងការអភិវឌ្ឍប្រព័ន្ធមូលដ្ឋាន និងនីតិវិធីសម្រាប់កម្រិតថ្នាក់ក្រោមជាតិក្នុងការកំណត់ប្រភពចំណូលមូលដ្ឋាន និងគ្រប់គ្រងការប្រមូលចំណូល។ បន្ទាប់មក ការបែងចែងសម្រាប់មូលនិធិឃុំក៏អាចរួមមានការផ្តត់ផ្គង់ដើម្បីកែសម្រួល ទំហំនៃប្រភពចំណូលមូលដ្ឋានដែលអាចមាន ជាមួយនឹងឃុំដែលមានសក្តានុពលបង្កើន ចំណូលតិចតួច ដើម្បីទទួលបានមូលនិធិពីថ្នាក់កណ្តាល។
- មានប្រភពផ្សេងៗ ដែលកំពុងហូរចូលទៅក្នុងឃុំ ជាមួយនឹងប្រភពមួយចំនួនដែលមិនបានធ្វើសមាហរ ណកម្មទៅក្នុងដំណើរការនៃការធ្វើការផែនការ និងថវិកាឃុំ។ គួរតែមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីសម្របសម្រួលឲ្យបានកាន់តែប្រសើរ សម្រាប់តួអង្គផ្តល់សេវា ហើយគួរផ្តល់ពេលវេលាបន្ថែមទៀត សម្រាប់ឃុំ ក្នុងការបញ្ជូនផែនការរបស់ខ្លួន ទៅសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ដើម្បីឲ្យអ្នកទាំងនោះយល់ដឹងអំពីប្រភពធនធាន ដែលនឹងអាចប្រើប្រាស់បាន។
- បង្កើនកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលនឹងអាចធ្វើឲ្យអាជ្ញាធរថ្នាក់ក្រោមជាតិបំពេញតួនាទី ដោយមានសិទ្ធិអំណាចកាន់តែច្រើន និងដោយឯករាជ្យក្នុងការលើកថវិកា និងការផ្តល់ សេវានានា។ ផ្ទុយទៅវិញ ការបណ្តុះបណ្តាលត្រូវធ្វើឡើងក្នុងបរិបទជាក់លាក់ និងមិនត្រូវធ្វើឲ្យរាំងស្ទះដល់ការផ្តួចផ្តើមនៅកម្រិតមូលដ្ឋានឡើយ។ ជម្រើសផ្សេងទៀតក្រៅពីការបណ្តុះបណ្តាលពីថ្នាក់កណ្តាល អាចរួមមានវេទិកាតាមមូលដ្ឋាន ដើម្បីផ្តល់ឱកាសសម្រាប់ការផ្លាស់ប្តូរគំនិតយោបល់ និងការសិក្សាពីគ្នាទៅវិញទៅមកនៅថ្នាក់ស្រុក និងទស្សនកិច្ចសិក្សាសម្រាប់ឃុំ ដើម្បីរៀនសូត្រពីការអនុវត្តហិរញ្ញវត្ថុបានល្អ នៅតាមតំបន់ផ្សេងទៀត។ យន្តការ

និងកាលានុវត្តភាពសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការធ្វើអន្តរកម្មជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិផ្សេងទៀត អង្គការសង្គមស៊ីវិល និងអ្នកធ្វើគោលនយោបាយ ចាំបាច់ត្រូវធ្វើការលើកកម្ពស់ដើម្បីជាមេរៀនសម្រាប់ការសិក្សាស្វែងយល់ និងសម្រាប់ការរៀបចំគោលនយោបាយ ឲ្យមានប្រសិទ្ធភាព។

- ពន្លឿនការទទួលបានព័ត៌មានអំពីច្បាប់គឺមានសារៈសំខាន់ណាស់។ ក៏ប៉ុន្តែមុនពេលដែលសម្រេចបានបញ្ហានេះ មានជំហានមួយចំនួនអាចត្រូវបានធ្វើឡើង ដើម្បីពង្រឹងតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងស្រុក ក្នុងការផ្តល់ព័ត៌មានស្តីពីវិធីសាស្រ្តនៃការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើផែនការ ការរៀបចំថវិកា និង ការត្រួតពិនិត្យសេវាកម្មតាមមូលដ្ឋាន និងការជម្រុញឲ្យអាជ្ញាធរមូលដ្ឋានទទួលខុសត្រូវ ដោយការប្រើប្រាស់បណ្តាញផ្សព្វផ្សាយក្នុងស្រុក និងទូរទស្សន៍ ដែលអាចផ្សព្វផ្សាយបាននៅទូទាំងប្រទេស។

វាចាំបាច់ណាស់ដែលកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មាន ″ស្ថាប័នជំនាញ″ ដែលមានឆន្ទៈក្នុងការតស៊ូមតិ ដើម្បីការសម្របសម្រួលកាន់តែប្រសើរជាងមុនរវាងតួអង្គនានា និង ដែលយល់អំពីតម្លៃ និងផលចំណេញនៃកំណែទម្រង់នេះ។ សភាគឺជាអ្នកដែលគាំទ្រលើកម្មវិធីនានាដែលម្ចាស់ឆ្នោតពេញចិត្ត និងការបំពេញតួនាទីតំណាងរបស់ខ្លួន ធ្វើឲ្យសមាជិកសភា យល់ច្បាស់អំពីកម្លាំងចលករ និង បញ្ហានៅថ្នាក់មូលដ្ឋាន ដែលផ្តល់ឲ្យសភានូវតួនាទីគន្លឹះក្នុងនាមជាស្ថាប័នជំនាញនៃកំណែទម្រង់ការអភិវឌ្ឍន៍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ជាពិសេស សមាជិកសភាអាចជួយតាមរយៈ ៖

- ការផ្តល់ព័ត៌មានដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋអំពីបទបញ្ញត្តិ និង ការកែតម្រូវការយល់ខុស អំពីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈវេទិកានៅថ្នាក់មូលដ្ឋាន ជាប់ជាប្រចាំ។
- ការលើកកម្ពស់គណនេយ្យភាពមូលដ្ឋាន ដោយការស្តាប់បញ្ហាកង្វល់របស់ប្រជាពលរដ្ឋ និងការដោះស្រាយបញ្ហាទាំងនេះជាមួយនឹងក្រុមប្រឹក្សាឃុំ/សង្កាត់ និងដាក់បញ្ចូលតម្រូវការ និងបញ្ហារួមរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរថ្នាក់ក្រោមជាតិទៅក្នុងដំណើរការអភិវឌ្ឍន៍គោលនយោបាយជាតិ។
- ការត្រួតពិនិត្យលើការបែងចែកថវិកាជាតិ។ ការត្រួតពិនិត្យរបស់អង្គនីតិប្បញ្ញត្តិលើបញ្ហាថវិកាគឺជាសិទ្ធិតាម រដ្ឋធម្មនុញ្ញ និងជួយធានាថាការបែងចែងនោះគឺស្របទៅតាមគោលបំណងនៃអាទិភាពគោលនយោបាយ និងតម្រូវការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម

ជាតិ។ ការណ៍នេះធ្វើឲ្យ សភាជម្រុញរដ្ឋាភិបាលឲ្យទទួលខុសត្រូវ ចំពោះលទ្ធផលនានា ជាពិសេសពាក់ព័ន្ធនឹងការអភិវឌ្ឍន៍តាម មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

- ការលើកកម្ពស់តម្លាភាពព័ត៌មាន។ ដើម្បីអភិវឌ្ឍការយល់ដឹងឲ្យកាន់តែប្រសើរ អំពីវិធីសាស្ត្រនៃការទទួលបានជំនួយនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងដើម្បីលើកកម្ពស់ដំណាក់កាលបន្ទាប់នៃកំណែទម្រង់ សមាជិកសភាគួរស្នើសុំព័ត៌មានបន្ថែមពីរាជរដ្ឋាភិបាលកម្ពុជា ស្តីពីធនធានសរុប ដែលត្រូវបានបែងចែក/ផ្តល់ដល់ថ្នាក់ក្រោមជាតិដែលបែងចែកតាមតំបន់ និងតាមវិស័យ។ សមាជិកសភាក៏អាចធ្វើការងារជួយពន្លឿនមធ្យោបាយនៃការទទួលបានព័ត៌មានអំពីច្បាប់ផងដែរ។

## គន្ថនិទ្ទេស

Ahmad J, Devarajan S, Khemani S និង Shah S. (២០០៥). វិមជ្ឈការ និងការផ្តល់សេវាកម្ម. *ឯកសារស្រាវជ្រាវអំពីគោលនយោបាយរបស់ធនាគារពិភពលោក លេខ៣៦០៣.* ទទួលបានពី http://papers.ssrn.com/sol3/papers.cfm?abstract_id=753505

Bahl R. (១៩៩៩). ការអនុវត្តច្បាប់សម្រាប់វិមជ្ឈការសារពើពន្ធ. *ឯកសារការងារនៃកម្មវិធីសិក្សាអន្តរជាតិ, ៣០.* ទទួលបានពី http://aysps.gsu.edu/isp/files/ispwp9901.pdf

Bank W. (២០០៥). *វិមជ្ឈការអាស៊ីខាងកើត៖ ការធ្វើឲ្យរដ្ឋាភិបាលមូលដ្ឋានដំណើរការ.* ឯកសារចេញផ្សាយរបស់ធនាគារពិភពលោក.

Bice K. (២០១០). *ការពង្រឹងអភិបាលកិច្ច និងវិមជ្ឈការមូលដ្ឋាន៖ មេរៀន និងបទពិសោធន៍ពីសមាគមរដ្ឋាភិបាលមូលដ្ឋាននៅអាស៊ី.* សហព័ន្ធនៃក្រុងនានានៃប្រទេសកាណាដា, VNGអន្តរជាតិ, លំដាប់នៃករណីសិក្សាស្តីពីការកសាងសមត្ថភាពសមាគមរដ្ឋាភិបាលមូលដ្ឋាន.

Blunh P និងTurner M. (២០០៥). វិមជ្ឈការ លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍនៅក្នុងសង្គមក្រោយជម្លោះ៖ ក្រុមប្រឹក្សាឃុំ/សង្កាត់នៅកម្ពុជា. *រដ្ឋបាលសាធារណៈ និងការអភិវឌ្ឍ, ២៥*(១), ៧៥-៨៧.

EIC. (២០១០). *របាយការណ៍នៃការស្ទង់មតិលើកទី២ស្តីពីការពេញចិត្តរបស់ប្រជាពលរដ្ឋនៅតាមឃុំ/សង្កាត់គោលដៅនៃគម្រោងLAAR.* វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា(EIC) តំណាងឲ្យកម្មវិធីរដ្ឋបាលមូលដ្ឋាន និងកំណែទម្រង់របស់អង្គការPact Cambodia, ភ្នំពេញ, កម្ពុជា. ទទួលបានពី http://www.pactcambodia.org/Publications/LAAR/2nd_Citizen_Satisfaction_Survey_Report_June2010.pdf

Eng N និងCraig D. (២០០៩). *គណនេយ្យភាព និងការគ្រប់គ្រងធនធានមនុស្សក្នុងការធ្វើវិមជ្ឈការនៅ កម្ពុជា.* កម្រងឯកសារការងាររបស់CDRI. វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍកម្ពុជា (CDRI), ភ្នំពេញ, កម្ពុជា. ទទួលបានពី http://www.cdri.org.kh/webdata/download/wp/wp40e.pdf

Gilfillan B. (២០០៨). *ការប្រើប្រាស់គោលនយោបាយចូលរួម៖ គណៈកម្មាធិការសុខភាពកម្ពុជា.* និក្ខេបបទ ថ្នាក់បណ្ឌិតដែលមិនបោះពុម្ពផ្សាយ. សកលវិទ្យាល័យស៊ីដនី, មហាវិទ្យាល័យសេដ្ឋកិច្ចនិងធុរកិច្ច, មុខវិជ្ជារដ្ឋាភិបាលនិងទំនាក់ទំនងអន្តរជាតិ.

Girishankar N, DeGroot D, Desai R, Stout S, និងWescott C. (២០១១). កម្ពុជា៖ ការផ្សាភ្ជាប់កម្រិតប្រទេសស្តីពីអភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយរបស់ធនាគារពិភពលោក. *ឯកសារការងាររបស់IEG ២០១១/៦.* ក្រុមវាយតម្លៃឯករាជ្យ(IEG), ក្រុមធនាគារពិភពលោក. ទទួលបានពី http://ieg.worldbankgroup.org/content/dam/ieg/gac/gac_eval.pdf

Horng V, Craig D និងKambuja VPP. (២០០៨). គណនេយ្យភាព និងការធ្វើផែនការនៅកម្ពុជាដែលបានធ្វើវិមជ្ឈការ. *កម្រងឯកសារការងាររបស់CDRI លេខ៣៩.* វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍកម្ពុជា(CDRI). ទទួលបានពី http://www.cdri.org.kh/webdata/download/wp/wp39e.pdf

Im S. (២០០៧). *ករណីសិក្សានៃក្រុមប្រឹក្សាឃុំ/សង្កាត់៖ ឯកសារនៃការអនុវត្តតែមួយ.* គម្រោងគាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់(CCSP), ភ្នំពេញ, កម្ពុជា.

Kim N និងHenke R. (២០០៥). *ក្រុមប្រឹក្សាឃុំ/សង្កាត់នៅកម្ពុជា៖ ការស្ទង់មតិថ្នាក់ជាតិស្តីពីមុខងារ និងការអនុវត្តរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ដោយផ្តោតសំខាន់លើការដោះស្រាយជម្លោះ.* អង្គការមូលនិធិអាស៊ី, ភ្នំពេញ, កម្ពុជា. ទទួលបានពី http://asiafoundation.org/pdf/CB-CCSurvey.pdf

Kimchoeun P. (២០១១). *វិមជ្ឈការសារពើពន្ធនៅកម្ពុជា៖ ការសិក្សាឡើងវិញនៃការវិវត្ត និងបញ្ហាប្រឈម*. កម្រងឯកសារការងារ. វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍកម្ពុជា(CDRI), ភ្នំពេញ, កម្ពុជា. ទទួលបានពី http://www.cdri.org.kh/webdata/download/wp/wp50e.pdf

Kuehi P. (២០១១). *ការវាយតម្លៃធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព-យុទ្ធសាស្ត្រសម្រាប់កម្រិតថ្នាក់ក្រោមជាតិ*(មិនបោះពុម្ពផ្សាយ). ឯកសារពិភាក្សាផ្ទៃក្នុងរបស់អង្គការGIZ, Gesellschaft Fur Internationale Zusammernarbeit(GIZ), ភ្នំពេញ, កម្ពុជា.

Malena C និងChhim K. (២០០៩). *ការផ្សាភ្ជាប់ប្រជាពលរដ្ឋនិងរដ្ឋ៖ ការវាយតម្លៃការចូលរួមរបស់សង្គមស៊ីវិលទៅក្នុងអភិបាលកិច្ចល្អនៅកម្ពុជា.* ការិយាល័យតំណាងរបស់ធនាគារពិភពលោកប្រចាំនៅកម្ពុជា. ទទួលបានពី http://siteresources.worldbank.org/EXTSOCIALDEVELOPMENT/Resources/244362-1193949504055/4348035-1296838689014/7712311-1298494972121/Assessment_CivilSocietyContributionsCambodia.pdf

Mansfield C និងMacleod M. (២០០៤). *ក្រុមប្រឹក្សាឃុំ/សង្កាត់ និងសង្គមស៊ីវិល៖ ការលើកកម្ពស់វិមជ្ឈការ តាមរយៈភាពជាដៃគូ*. អង្គការPact Cambodia, ភ្នំពេញ, កម្ពុជា. ទទួលបានពី http://www.pactcambodia.org/Publications/Decentralization/Commune_Council_&_Civil_Society.pdf

Martinez-Vazquez J និងMcNab R. (២០០១). វិមជ្ឈការសារពើពន្ធ និងកំណើនសេដ្ឋកិច្ច. *Georgia State Andrew Young School of Policy (ISP) Working Paper No. 01-01*. ទទួលបានពី http://papers.ssrn.com/sol3/papers.cfm?abstract_id=259281

Mehrotra S. (២០០៦). អភិបាលកិច្ច និងសេវាកម្មសង្គមមូលដ្ឋាន៖ ការធានាគណនេយ្យភាពនៅក្នុងការផ្តល់សេវាកម្មតាមរយៈវិមជ្ឈការបែបប្រជាធិបតេយ្យ ដែលស៊ីជម្រៅជាងមុន។ *ព្រឹត្តប័ត្រការអភិវឌ្ឍអន្តរជាតិ, ១៨*(២), ២៦៣-២៨៣.

ក្រសួងមហាផ្ទៃ. (២០០៨). *ការវិភាគស្ថានភាពរដ្ឋបាល ខេត្ត/រាជធានី និងស្រុក/ខណ្ឌ នៅកម្ពុជា។* ក្រសួង មហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា, អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, គម្រោងស្តីពីការលើកកម្ពស់រដ្ឋបាលមូល ដ្ឋាននៅកម្ពុជា(PILAC), ភ្នំពេញ, កម្ពុជា.

ក្រសួងផែនការ. (២០១០). *ភាពក្រីក្រ និងការជ្រើសរើសផែនទីនិងតារាងCMDGs ២០០៣-២០០៩.* ក្រសួងផែនការ(MoP), ព្រះរាជាណាចក្រកម្ពុជា(RGC), ភ្នំពេញ, កម្ពុជា.

ក្រសួងផែនការ/UNDP. (២០០៧). *របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជាឆ្នាំ២០០៧៖ ការពង្រីកជម្រើសសម្រាប់ប្រជាជននៅតំបន់ដាច់ស្រយាល។* ក្រសួងផែនការ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ, ភ្នំពេញ, កម្ពុជា. ទទួលបានពី
http://hdr.undp.org/en/reports/nationalreports/asiathepacific/cambodia/Cambodia_HDR_2007.pdf

Ndaruhutse S. (២០១១). *ការកសាងរដ្ឋ ការកសាងសន្តិភាព និងការផ្តល់សេវានៅក្នុងរដ្ឋទន់ខ្សោយ និងរងឥទ្ធិពលដោយសារជម្លោះ, ករណីសិក្សា៖កម្ពុជា.* នាយកដ្ឋានដើម្បីការអភិវឌ្ឍអន្តរជាតិរបស់UK.ទទួលបានពី http://practicalaction.org/media/view/16478

NCDD. (២០០៨a). *ការឆ្លើយតបនៃផែនការអភិវឌ្ឍឃុំ/សង្កាត់ និងកម្មវិធីវិនិយោគឃុំ/សង្កាត់ចំពោះតម្រូវការការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ឃុំ និងCMDGs - ការសិក្សា.* គណកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD), ភ្នំពេញ, កម្ពុជា.

NCDD. (២០០៨b). *ការស្ទង់មតិស្តីពីទំហំលទ្ធផលដែលបានជ្រើសរើសនៃកម្មវិធីNCDD/PSDD.* គណកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD), ភ្នំពេញ, កម្ពុជា.

NCDD. (២០១០a). *ការវិភាគលើកម្មវិធីសម្រង់ស្ថិតិការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់.* គណកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD), ភ្នំពេញ, កម្ពុជា.

NCDD. (២០១០b). *ដំណើរការសវនកម្មស្តីពីការធ្វើផែនការថវិកាឃុំ/សង្កាត់ឆ្នាំ២០០៩។* គណកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD), ភ្នំពេញ, កម្ពុជា.

NCDD. (២០១១). *ការសិក្សាស្តីពីការអភិវឌ្ឍធនធានមនុស្ស៖ កម្មវិធីបណ្តុះបណ្តាលស្តីពីរដ្ឋបាលមូលដ្ឋានសម្រាប់មន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ.* គណកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជា

ធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD), គម្រោងអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការអនុវត្តច្បាប់អង្គការនៅថ្នាក់រាជធានី និងខេត្ត (PILAC 2), ភ្នំពេញ, កម្ពុជា.

NLC/S. (២០០៩). *ការអនុវត្ត និងបញ្ហាប្រឈមរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់៖ ការសិក្សាឡើងវិញលើប្រភពឯកសារប្រភេទទី២*. សម្ព័ន្ធភាពជាតិឃុំ/សង្កាត់(NLC/S), ភ្នំពេញ, កម្ពុជា.

NLC/S. (២០១១a). *កញ្ចប់នៃអ្នកចាប់ផ្តើមអនុវត្ត៖ មុខងារឃុំ និងសង្កាត់*. ឯកសារមិនបោះពុម្ពផ្សាយ. សម្ព័ន្ធភាពជាតិឃុំ/សង្កាត់(NLC/S), ភ្នំពេញ, កម្ពុជា.

NLC/S. (២០១១b). *ក្រុមប្រឹក្សាដែលមានសមត្ថភាព៖ ការស្ទង់មតិថ្នាក់ជាតិស្តីពីការទទួលខុសត្រូវសមត្ថភាព និងការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ/សង្កាត់*. ឯកសារមិនបោះពុម្ពផ្សាយ. សម្ព័ន្ធភាពជាតិឃុំ/សង្កាត់(NLC/S), ភ្នំពេញ, កម្ពុជា.

Ojendal J និងSedara K. (ពុំមានកាលបរិច្ឆេទ). ការសិក្សាពីសាវតាស្តីពីតួនាទី និងសក្តានុពលការិយាល័យ ស្រុកដែលកំពុងប្រឈមនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ. ឯកសារមិនបោះពុម្ពផ្សាយ.

Pak K. (២០១១). វិមជ្ឈការសារពើពន្ធនៅកម្ពុជា៖ ការសិក្សាឡើងវិញនៃការវិវត្ត និងបញ្ហាប្រឈម. *កម្រងឯកសារការងាររបស់CDRI លេខ៥០*. វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍន៍កម្ពុជា(CDRI), ភ្នំពេញ, កម្ពុជា. ទទួលបានពី http://www.cdri.org.kh/webdata/download/wp/wp50e.pdf

Pak K និងCraig D. (២០០៨). *គណនេយ្យភាព និងការគ្រប់គ្រងការចំណាយសាធារណៈនៅកម្ពុជាដែលបានធ្វើវិមជ្ឈការ*. កម្រងឯកសារការងាររបស់CDRI. ភ្នំពេញ៖ វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍន៍កម្ពុជា(CDRI). ទទួលបានពី
http://www.cdri.org.kh/webdata/download/wp/wp38e.pdf

Pak K, Horng V, Sovatta A និងNgoun Ngo T. (២០០៥). *ការពង្រឹងអភិបាលកិច្ចថ្នាក់ខេត្តនៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា៖ គណនេយ្យភាពនៅក្នុងប្រព័ន្ធគ្រប់គ្រងថ្មី*. ឯកសាររៀបចំគម្រោង. វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍន៍កម្ពុជា(CDRI). ទទួលបានពី
http://www.cdri.org.kh/webdata/pordec/accstudyAug05.pdf

Pellini A. (២០០៧). *គោលនយោបាយវិមជ្ឈការនៅកម្ពុជា*. សកលវិទ្យាល័យTampere. និក្ខេបបទថ្នាក់បណ្ឌិតដែលមិនបោះពុម្ពផ្សាយ. ទទួលបានពី http://unpan1.un.org/intradoc/groups/public/documents/un-dpadm/unpan042157.pdf

Prum S. (២០០៥). *វិមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា៖ បទពិសោធន៍ និងបញ្ហាប្រឈម*. សិក្ខាសាលាអន្តរជាតិ ស្តីពី“វិមជ្ឈការ៖ ការកាត់បន្ថយភាពក្រីក្រ ការផ្តល់សិទ្ធិអំណាច និងការចូលរួម”, រដ្ឋាភិបាលQueensland/UNDESA. ទទួលបានពី http://unpan1.un.org/intradoc/groups/public/documents/un/unpan020699.pdf

រាជរដ្ឋាភិបាលកម្ពុជា. (២០០៥). *ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ*. ព្រះរាជាណាចក្រកម្ពុជា(RGC), ភ្នំពេញ, កម្ពុជា.

រាជរដ្ឋាភិបាលកម្ពុជា. (២០១០a). *កម្មវិធីជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NP-SNDD) ឆ្នាំ២០១០-២០១៩*. ព្រះរាជាណាចក្រកម្ពុជា(RGC).

រាជរដ្ឋាភិបាលកម្ពុជា. (២០១០b). ផែនការអនុវត្តន៍រយៈពេល៣ឆ្នាំដំបូងនៃNP-SNDD(IP3). ព្រះរាជាណា-ចក្រកម្ពុជា(RGC), ភ្នំពេញ, កម្ពុជា.

Romeo L G និងSpyckerelle L. (២០០៣). *កំណែទម្រង់វិមជ្ឈការ និងការផ្តល់សេវាកម្មនៅថ្នាក់ឃុំ/សង្កាត់នៅកម្ពុជា*. ឯកសារមិនបោះពុម្ពផ្សាយ. ទទួលបានពី http://www.oecd.org/dataoecd/51/63/33742461.pdf

Rusten C និងKambuja V P P. (២០០៤). *បញ្ហាប្រឈមនៃការរៀបចំវិមជ្ឈការនៅកម្ពុជា*. វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍន៍កម្ពុជា, ភ្នំពេញ. ទទួលបានពី http://www.cdri.org.kh/webdata/pordec/decendesign.pdf

Ryutaro Murotani, Eiji Wakamatsu, Tomonori Kikuchi, Masafumi Nagaishi និងNaoyuki Ochiai. (២០១០). ការកសាងរដ្ឋនៅក្នុងស្ថានភាពផុយស្រួយ៖ បទពិសោធន៍ជំនួយរបស់ជប៉ុននៅកម្ពុជា អាហ្គានី-ស្ថាន និងមីនតាណាអូ(Mindanao). *ឯកសារការងាររបស់អង្គការJICA លេខ៥*, វិទ្យាស្ថានស្រាវជ្រាវភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA). ទទួលបានពី http://jica-ri.jica.go.jp/publication/assets/JICA-RI_WP_No.5_2010.pdf

Scott Z. (២០០៩). *វិមជ្ឈការ ការអភិវឌ្ឍមូលដ្ឋាន និងភាពប្រទាក់ក្រឡានៃសង្គម៖ ការសិក្សាវិភាគឡើងវិញ.* សកលវិទ្យាល័យបើមីងហោម. មជ្ឈមណ្ឌលធនធានអភិវឌ្ឍសង្គម និងអភិបាលកិច្ច (GSDRC). ទទួលបានពី http://www.gsdrc.org/docs/open/PO60.pdf

Sedara K, Ojendal J និងSovatha A. (២០០៧). *តើនៅចំណុចណាដែលវិមជ្ឈការជួបជាមួយលទ្ធិប្រជាធិបតេយ្យ៖ សង្គមស៊ីវិល រាជរដ្ឋាភិបាលមូលដ្ឋាន និងគណនេយ្យភាពនៅកម្ពុជា.* វិទ្យាស្ថានធនធានដើម្បីការអភិវឌ្ឍន៍កម្ពុជា(CDRI), ភ្នំពេញ, កម្ពុជា. ទទួលបានពី http://www.cdri.org.kh/webdata/download/wp/wp35e.pdf

Smoke P និងMorrison J. (២០០៨). វិមជ្ឈការនៅកម្ពុជា៖ ការពង្រឹងអំណាចថ្នាក់កណ្ដាល ឬការកសាងគណនេយ្យភាពពីថ្នាក់ក្រោម? *កម្រងឯកសារស្រាវជ្រាវរបស់កម្មវិធីសិក្សាអន្តរជាតិ, នៅ AYSPS, GSU.* ទទួលបានពី http://ideas.repec.org/p/ays/ispwps/paper0836.html

Spyckerelle L និងMorrison J. (២០០៧). ប្រព័ន្ធនៅក្នុងការរង់ចាំ៖ ការលើកកម្ពស់ការផ្ដល់សេវាកម្មតាមរយៈកំណែទម្រង់វិមជ្ឈការនៅកម្ពុជា. *IDS Bulletin, ៣៨*(១), ៦០-៦៩. Turner M. (២០០២). តើអ្វីខ្លះបានកើតឡើងចំពោះវិសហមជ្ឈការ? ការផ្ដួចផ្ដើមថ្មីៗនៅកម្ពុជា. *រដ្ឋបាលសាធារណៈ និងការអភិវឌ្ឍ, ២២*(៤), ៣៥៣-៣៦៤.

UNCDF. (២០១០). *ការប្រមើលមើលការអភិវឌ្ឍតាមមូលដ្ឋាននៅកម្ពុជា៖ និន្នាការ - គោលនយោបាយ -អភិបាលកិច្ច.* មូលនិធិអភិវឌ្ឍន៍ទុនសហប្រជាជាតិ(UNCDF), ភ្នំពេញ, កម្ពុជា.

UNDP. (២០០៨). *វិមជ្ឈការតាមបែបប្រជាធិបតេយ្យសម្រាប់រាជរដ្ឋាភិបាលមូលដ្ឋាន៖ ការផ្ដល់ប្រឹក្សាអំពីកិច្ចសហប្រតិបត្តិការអន្តរឃុំ/សង្កាត់ សម្រាប់គម្រោងសេវាកម្ម.* កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP), ភ្នំពេញ, កម្ពុជា.

Vedeld T. (២០០៣). វិមជ្ឈការតាមបែបប្រជាធិបតេយ្យ និងការកាត់បន្ថយភាពក្រីក្រ៖ ការស្វែងរកទំនាក់ទំនង. *វេទិកាសម្រាប់ការសិក្សាអំពីការអភិវឌ្ឍ*(លេខ ៣០ ទំព័រ ១៥៩-២០៣). ទទួលបានពី http://www.tandfonline.com/doi/abs/10.1080/08039410.2003.9666243

ធនាគារពិភពលោក. (២០០៤). *កម្ពុជានៅផ្លូវបំបែក៖ ការពង្រឹងគណនេយ្យភាពដើម្បីកាត់បន្ថយភាពក្រីក្រ.* ធនាគារពិភពលោកនៅតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិច. ទទួលបានពី

http://www-wds.worldbank.org/external/default/WDSContentServer/WDSP/IB/2005/08/09/000160016_20050809181530/Rendered/PDF/306360ENGLISH0KH0white0cover01public1.pdf

Young S. (២០០៩). *អភិបាលកិច្ចមូលដ្ឋាននៅក្នុងការធ្វើវិមជ្ឈការរដ្ឋបាលមូលដ្ឋាននៅកម្ពុជា៖ ករណីសិក្សា នៃក្រុមប្រឹក្សាឃុំ/សង្កាត់.* សារណាថ្នាក់អនុបណ្ឌិតដែលមិនបោះពុម្ពផ្សាយ. វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី, ផ្នែក បរិស្ថានធនធាន និងការអភិវឌ្ឍ, បាងកក, ប្រទេសថៃ.

## ប្រភពព័ត៌មានពីអ៊ីនធើណេត៖

MoI/DoLA. (ពុំមានកាលបរិច្ឆេទ). ក្រសួងមហាផ្ទៃ៖នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន-ហិរញ្ញវត្ថុឃុំ/សង្កាត់ ចំណូលមូលនិធិឃុំ/សង្កាត់. ទទួលបាននៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ពី http://www.moi-dola.gov.kh/kh/cspage/csfinance/csfundincome/

NCDD. (ពុំមានកាលបរិច្ឆេទ-a). គណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ៖ កម្មវិធីសម្រង់ស្ថិតិការធ្វើផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់(CDPD). កម្មវិធីសម្រង់ស្ថិតិ. ទទួលបាននៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២ ពី http://www.ncdd.gov.kh/en/resources/database/commune-development-planning-database-cdpd

NCDD. (ពុំមានកាលបរិច្ឆេទ-b). គណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ៖ កម្មវិធីសម្រង់ស្ថិតិព័ត៌មានអំពីគម្រោង(PID)នៅលើគេហទំព័រ. កម្មវិធីសម្រង់ស្ថិតិ. ទទួលបាននៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ពី http://db.ncdd.gov.kh/pid/home/index.castle

## បទសម្ភាសន៍៖

លោកPeter Becker នាយកស្តីទីផ្នែកស្រាវជ្រាវ របស់វិទ្យាស្ថានសភាកម្ពុជា. (ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២).

លោក មិន មុន្នី អ្នកសម្របសម្រួលថ្នាក់ជាតិ, ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍, កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP). (ថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០១២).

លោក ជា គឹមសុង អ្នកគ្រប់គ្រងកម្មវិធីបញ្ហាការអភិវឌ្ឍន៍, អង្គការINGO Forumនៅកម្ពុជា. (ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២).

លោក គិន ពិសី អ្នកស្រាវជ្រាវ, វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា. (ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១២).

លោក ហេង សុជាតិ អ្នកគ្រប់គ្រងកម្មវិធីថ្នាក់ជាតិ, កម្មវិធីពង្រឹងលទ្ធិប្រជាធិបតេយ្យ, UNDP. (ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២).

លោក Scott Leiper ទីប្រឹក្សាជាន់ខ្ពស់ផ្នែកកម្មវិធី, គណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិ. (ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២).

លោក ស្រេង សុភាព មន្ត្រីគម្រោង, ការប្រមូលផ្តុំសហគមន៍សម្រាប់ការលើកកម្ពស់សេវាកម្មសង្គម(CMPSS), NCDD. (ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២).

លោក ទូច ប៉ុលពន្លក ទីប្រឹក្សាជាន់ខ្ពស់ផ្នែកគោលនយោបាយថ្នាក់ជាតិ, គណៈកម្មាធិការជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD). (ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២).

លោកស្រី Katharina Huber អ្នកសម្របសម្រួលកម្មវិធី, កម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ, អង្គការ GIZ, កម្ពុជា. (ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២).

លោក ប៉ុក សុគន្ធតារា អគ្គលេខាធិការ, សម្ព័ន្ធភាពជាតិឃុំ/សង្កាត់(NLC/S). (ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២).

លោក ប៊ូ វង្សសុខា អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. (ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១២០.